# ព្រះ
# ត្រៃបិដកបាលី
និង
## សេចក្ដីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
## យមក ទុតិយភាគ

# ៤៨

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស ២៥០៩

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥០០០ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សារ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនពីសំណាក់៖

- ឧបាសិកា កាំង ហ្គិចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាវៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវុត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតន៍ ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផេង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីសក់ ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា សែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ដុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
# យមក ទុតិយភាគ

# ៨៨

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៩

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ចង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្ដីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្ដេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未會有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# អភិធម្មបិដក

## យមក ទុតិយភាគ

៨៨

ព. ស. ២៥០៩

# អភិធម្មបិដកេ

# យមកស្ស ទុតិយោ ភាគោ

## ធាតុយមកំ

### បណ្ណត្តិវារោ

(១) អដ្ឋារស ធាតុយោ ចក្ខុធាតុ សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ រសធាតុ ផោដ្ឋព្វធាតុ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ មនោធាតុ មនោវិញ្ញាណធាតុ ធម្មធាតុ ។

### និទ្ទេសវារោ

(២) ចក្ខុ ចក្ខុធាតុ ចក្ខុធាតុ ចក្ខុ ។ សោតំ សោតធាតុ សោតធាតុ សោតំ ។ បេ ។ ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណធាតុ ចក្ខុវិញ្ញាណធាតុ ចក្ខុវិញ្ញាណំ ។ បេ ។ មនោ មនោធាតុ មនោធាតុ មនោ ។ មនោវិញ្ញាណំ មនោវិញ្ញាណធាតុ មនោវិញ្ញាណធាតុ មនោវិញ្ញាណំ ។ ធម្មោ ធម្មធាតុ ធម្មធាតុ ធម្មោ ។

# អភិធម្មបិដក

# យមក ទុតិយភាគ

---

## ធាតុយមកៈ

### បណ្ណត្តិវារៈ

(១) ធាតុ ១៨ គឺ ចក្ខុធាតុ ១ សោតធាតុ ១ ឃានធាតុ ១ ជិវ្ហាធាតុ ១ កាយធាតុ ១ រូបធាតុ ១ សទ្ទធាតុ ១ គន្ធធាតុ ១ រសធាតុ ១ ផោដ្ឋព្វធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញាណធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណធាតុ ១ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ ធម្មធាតុ ១ ។

### ឧទ្ទេសវារៈ

(២) ចក្ខុ ហៅថាចក្ខុធាតុ ចក្ខុធាតុ ហៅថាចក្ខុ ។ សោតៈ ហៅថាសោតធាតុ សោតធាតុ ហៅថាសោតៈ ។ បេ ។ ចក្ខុវិញ្ញាណ ហៅថាចក្ខុវិញ្ញាណធាតុ ចក្ខុវិញ្ញាណធាតុ ហៅថាចក្ខុវិញ្ញាណ ។ បេ ។ មនៈ ហៅថាមនោធាតុ មនោធាតុ ហៅថាមនៈ ។ មនោវិញ្ញាណ ហៅថាមនោវិញ្ញាណធាតុ មនោវិញ្ញាណធាតុ ហៅថាមនោវិញ្ញាណ ។ ធម៌ ហៅថាធម្មធាតុ ធម្មធាតុ ហៅថាធម៌ ។

(៣) ន ចក្ខុ ន ចក្ខុធាតុ ន ចក្ខុធាតុ ន ចក្ខុ ។ ន សោតំ ន សោតធាតុ ន សោតធាតុ ន សោតំ ។ បេ ។ ន ចក្ខុវិញ្ញាណំ ន ចក្ខុវិញ្ញាណធាតុ ន ចក្ខុវិញ្ញាណធាតុ ន ចក្ខុវិញ្ញាណំ ។ បេ ។ ន មនោ ន មនោធាតុ ន មនោធាតុ ន មនោ ។ ន មនោវិញ្ញាណំ ន មនោវិញ្ញាណធាតុ ន មនោវិញ្ញាណធាតុ ន មនោវិញ្ញាណំ ។ ន ធម្មោ ន ធម្មធាតុ ន ធម្មធាតុ ន ធម្មោ ។

(៤) ចក្ខុ ចក្ខុធាតុ ធាតូ[១] សោតធាតុ ។ បេ ។ ចក្ខុ ចក្ខុធាតុ ធាតូ ធម្មធាតុ ។ យថា អាយតនយមកេ ចក្កំ ពន្ធិតំ[២] ឯវមិធ[៣] ចក្កំ ពន្ធិតព្វំ ។

(៥) ន ចក្ខុ ន ចក្ខុធាតុ ន ធាតូ ន សោតធាតុ ។ ន ចក្ខុ ន ចក្ខុធាតុ ន ធាតូ ន ឃានធាតុ ។ បេ ។ ន ចក្ខុ ន ចក្ខុធាតុ ន ធាតូ ន ធម្មធាតុ ។ បេ ។ ន ធម្មោ ន ធម្មធាតុ ន ធាតូ ន ចក្ខុធាតុ ។ បេ ។ ន ធម្មោ ន ធម្មធាតុ ន ធាតូ ន មនោវិញ្ញាណធាតុ ។ ចក្កំ ពន្ធិតព្វំ ។

---

១ ម. ធាតុ ។ ២ ម. ពន្ធំ ។ ៣ ម. ឥធសព្វេ នត្ថិ ។

(៣) មិនមែនចក្ខុ មិនហៅថាចក្ខុធាតុ មិនមែនចក្ខុធាតុ មិនហៅថាចក្ខុ ។ មិនមែនសោតៈ មិនហៅថាសោតធាតុ មិនមែនសោតធាតុ មិនហៅថាសោតៈ ។ បេ ។ មិនមែនចក្ខុវិញ្ញាណ មិនហៅថាចក្ខុវិញ្ញាណធាតុ មិនមែនចក្ខុវិញ្ញាណធាតុ មិនហៅថាចក្ខុវិញ្ញាណ ។ បេ ។ មិនមែនមនៈ មិនហៅថាមនោធាតុ មិនមែនមនោធាតុ មិនហៅថាមនៈ ។ មិនមែនមនោវិញ្ញាណ មិនហៅថាមនោវិញ្ញាណធាតុ មិនមែនមនោវិញ្ញាណធាតុ មិនហៅថាមនោវិញ្ញាណ ។ មិនមែនធម៌ មិនហៅថាធម្មធាតុ មិនមែនធម្មធាតុ មិនហៅថាធម៌ ។

(៤) ចក្ខុ ហៅថាចក្ខុធាតុ ធាតុទាំងឡាយ ហៅថាសោតធាតុ ។ បេ ។ ចក្ខុ ហៅថាចក្ខុធាតុ ធាតុទាំងឡាយ ហៅថាធម្មធាតុ ។ ចក្រ ដែលលោកចង ក្នុងអាយតនយមកៈ យ៉ាងណា ចក្រ ដែលលោកចង ក្នុងធាតុយមកៈនេះ យ៉ាងនោះដែរ ។

(៥) មិនមែនចក្ខុ មិនហៅថាចក្ខុធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាសោតធាតុ ។ មិនមែនចក្ខុ មិនហៅថាចក្ខុធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាឃានធាតុ ។ បេ ។ មិនមែនចក្ខុ មិនហៅថាចក្ខុធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាធម្មធាតុ ។ បេ ។ មិនមែនធម៌ មិនហៅថាធម្មធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាចក្ខុធាតុ ។ បេ ។ មិនមែនធម៌ មិនហៅថាធម្មធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាមនោវិញ្ញាណធាតុ ។ ចក្រ បណ្ឌិតគប្បីចង ។

ធាតុយមកេ បណ្ណត្តិវារស្ស ឧទ្ទេសោ

(៦) ចក្ខុ ធាតុ ធាតុ ចក្ខុ ។ សោតំ ធាតុ ធាតូ សោតំ ។ ឃានំ ជិវ្ហា កាយោ រូបំ សទ្ទោ គន្ធោ រសោ ផោដ្ឋព្វោ ។ ចក្ខុវិញ្ញាណំ ធាតុ ធាតូ ចក្ខុវិញ្ញាណំ ។ សោតវិញ្ញាណំ ធាតុ ធាតូ សោតវិញ្ញាណំ ។ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ ។ មនោ ធាតុ ធាតូ មនោ ។ មនោវិញ្ញាណំ ធាតុ ធាតូ មនោវិញ្ញាណំ ។ ធម្មោ ធាតុ ធាតូ ធម្មោ ។

(៧) ន ចក្ខុ ន ធាតុ ន ធាតូ ន ចក្ខុ ។ ន សោតំ ន ធាតុ ន ធាតូ ន សោតំ ។ ន ឃានំ ន ជិវ្ហា ន កាយោ ន រូបំ ន សទ្ទោ ន គន្ធោ ន រសោ ន ផោដ្ឋព្វោ ។ ន ចក្ខុវិញ្ញាណំ ន ធាតុ ន ធាតូ ន ចក្ខុវិញ្ញាណំ ។ ន សោតវិញ្ញាណំ ន ឃានវិញ្ញាណំ ន ជិវ្ហាវិញ្ញាណំ ។ ន កាយវិញ្ញាណំ ន ធាតុ ន ធាតូ ន កាយវិញ្ញាណំ ។ ន មនោ ន ធាតុ ន ធាតូ ន មនោ ។

ធាតុយមកៈ បណ្ណត្តិវារៈ ឧទ្ទេស

(៦) ចក្ខុ ហៅថាធាតុ ធាតុ ហៅថាចក្ខុ ។ សោតៈ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាសោតៈ ។ ប្រមុះ អណ្ដាត កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។ ចក្ខុវិញ្ញាណ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាចក្ខុវិញ្ញាណ ។ សោតវិញ្ញាណ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាសោតវិញ្ញាណ ។ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ។ មនៈ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាមនៈ ។ មនោវិញ្ញាណ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាមនោវិញ្ញាណ ។ ធម៌ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាធម៌ ។

(៧) មិនមែនចក្ខុ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាចក្ខុ ។ មិនមែនសោតៈ មិនហៅថាធាតុ មិនមែនធាតុទាំង-ឡាយ មិនហៅថាសោតៈ ។ មិនមែនប្រមុះ មិនមែនអណ្ដាត មិនមែនកាយ មិនមែនរូប មិនមែនសំឡេង មិនមែនក្លិន មិនមែនរស មិនមែនផោដ្ឋព្វៈ ។ មិនមែនចក្ខុវិញ្ញាណ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាចក្ខុវិញ្ញាណ ។ មិនមែនសោតវិញ្ញាណ មិនមែនឃានវិញ្ញាណ មិនមែនជិវ្ហាវិញ្ញាណ ។ មិនមែនកាយវិញ្ញាណ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាកាយវិញ្ញាណ ។ មិនមែនមនៈ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាមនៈ ។

ន មនោវិញ្ញាណំ ន ធាតុ ន ធាតូ ន មនោវិញ្ញា-ណំ ។ ន ធម្មោ ន ធាតុ ន ធាតូ ន ធម្មោ ។

(៨) ចក្ខុ ធាតុ ធាតូ សោតំ ។ បេ ។ ចក្ខុ-ធាតុ ធាតូ ធម្មោ ។ បេ ។ ធម្មោ ធាតុ ធាតូ ចក្ខុ ។ បេ ។ ធម្មោ ធាតុ ធាតូ មនោវិញ្ញាណំ ។ ចក្កំ ពន្ធិតព្វំ ។

(៩) ន ចក្ខុ ន ធាតុ ន ធាតូ ន សោតំ ។ ន ចក្ខុ ន ធាតុ ន ធាតូ ន ឃានំ[១] ។ បេ ។ ន ចក្ខុ ន ធាតុ ន ធាតូ ន ធម្មោ ។ បេ ។ ន ធម្មោ ន ធាតុ ន ធាតូ ន ចក្ខុ ។ បេ ។ ន ធម្មោ ន ធាតុ ន ធាតូ ន មនោវិញ្ញាណំ ។ ចក្កំ ពន្ធិតព្វំ ។

ឧទ្ទេសវារោ[២] ។

## និទ្ទេសវារោ[៣]

(១០) ចក្ខុ ចក្ខុធាតូតិ ។ ទិព្វចក្ខុ បញ្ញាចក្ខុ

---

១ ឱ. ន ធាតូ ន ធម្មោតិ ទិស្សតិ ។ ២ ឱ. ឧទ្ទេសវារំ និដ្ឋិតន្តិ ទិស្សតិ ។ ម. ឧទ្ទេសវារោ នត្ថិ ។ ៣ ឱ. បណ្ណត្តិវារោតិ ទិស្សតិ ។ ម. និទ្ទេសវារោ នត្ថិ ។

មិនមែនមនោវិញ្ញាណ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាមនោវិញ្ញាណ ។ មិនមែនធម៌ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាធម៌ ។

(៨) ចក្ខុ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាសោត: ។ បេ ។ ចក្ខុ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាធម៌ ។ បេ ។ ធម៌ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាចក្ខុ ។ បេ ។ ធម៌ ហៅថាធាតុ ធាតុទាំងឡាយ ហៅថាមនោវិញ្ញាណ ។ ចក្រ បណ្ណតិគប្បីចង ។

(៩) មិនមែនចក្ខុ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាសោត: ។ មិនមែនចក្ខុ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាឃាន: ។ បេ ។ មិនមែនចក្ខុ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាធម៌ ។ បេ ។ មិនមែនធម៌ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាចក្ខុ ។ បេ ។ មិនមែនធម៌ មិនហៅថាធាតុ មិនមែនធាតុទាំងឡាយ មិនហៅថាមនោវិញ្ញាណ ។ ចក្រ បណ្ណតិគប្បីចង ។

ចប់ឧទ្ទេសវារៈ ។

## និទ្ទេសវារៈ

(១០) សួរ: ចក្ខុ ហៅថាធាតុឬ ។ ឆ្លើយ: ទិព្វចក្ខុ បញ្ញាចក្ខុ

ធាតុយមកេ បណ្ណត្តិវារស្ស និទ្ទេសោ

ចក្ខុ ន ចក្ខុធាតុ ចក្ខុធាតុ ចក្ខុ ចេវ ចក្ខុធាតុ ច ។ ចក្ខុធាតុ ចក្ខូតិ ។ អាមន្តា ។ សោតំ សោតធាតូតិ ។ ទិព្វសោតំ តណ្ហាសោតំ សោតំ ន សោតធាតុ សោតធាតុ សោតញ្ចេវ សោតធាតុ ច ។ សោតធាតុ សោតន្តិ ។ អាមន្តា ។ ឃានំ ឃានធាតូតិ ។ អាមន្តា ។ ឃានធាតុ ឃានន្តិ ។ អាមន្តា ។ ជិវ្ហាបិ ឃានធាតុសទិសា ។ កាយោ កាយធាតូតិ ។ កាយធាតុំ ឋបេត្វា អវសេសោ កាយោ កាយោ ន កាយធាតុ កាយធាតុ កាយោ ចេវ កាយធាតុ ច ។ កាយធាតុ កាយោតិ ។ អាមន្តា ។ រូបំ រូបធាតូតិ ។ រូបធាតុំ ឋបេត្វា អវសេសំ រូបំ រូបំ ន រូបធាតុ រូបធាតុ រូបញ្ចេវ រូបធាតុ ច ។ រូបធាតុ រូបន្តិ ។ អាមន្តា ។ សទ្ទោ ឃានសទិសោ ។ គន្ធោ គន្ធធាតូតិ ។ សីលគន្ធោ សមាធិគន្ធោ បញ្ញាគន្ធោ គន្ធោ ន គន្ធធាតុ គន្ធធាតុ គន្ធោ ចេវ គន្ធធាតុ ច ។ គន្ធធាតុ គន្ធោតិ ។ អាមន្តា ។ រសោ រសធាតូតិ ។ អត្ថរសោ

ធាតុយមកៈ បណ្ណត្តិវារៈ និទ្ទេស

ហៅថាចក្ខុ មិនហៅថាចក្ខុធាតុទេ ឯចក្ខុធាតុ ហៅថាចក្ខុផង ហៅថាចក្ខុធាតុផង ។ ចក្ខុធាតុ ហៅថាចក្ខុឬ ។ អើ ។ សោតៈ ហៅថាសោតធាតុឬ ។ ទិព្វសោតៈ តណ្ហាសោតៈ ហៅថាសោតៈ មិនហៅថាសោតធាតុទេ ឯសោតធាតុ ហៅថាសោតៈផង ហៅថាសោតធាតុផង ។ សោតធាតុ ហៅថាសោតៈឬ ។ អើ ។ ឃានៈ ហៅថាឃានធាតុឬ ។ អើ ។ ឃានធាតុ ហៅថាឃានៈឬ ។ អើ ។ ជិវ្ហា ដូចគ្នានឹងឃានធាតុ ។ កាយ ហៅថាកាយធាតុឬ ។ កាយដ៏សេស វៀរលែងកាយធាតុចេញ ហៅថាកាយ មិនហៅថាកាយធាតុទេ ឯកាយធាតុ ហៅថាកាយផង ហៅថាកាយធាតុផង ។ កាយធាតុ ហៅថាកាយឬ ។ អើ ។ រូប ហៅថារូបធាតុឬ ។ រូបដ៏សេស វៀរលែងរូបធាតុចេញ ហៅថារូប មិនហៅថារូបធាតុទេ ឯរូបធាតុ ហៅថារូបផង ហៅថារូបធាតុផង ។ រូបធាតុ ហៅថារូបឬ ។ អើ ។ សទ្ទៈ ដូចគ្នានឹងឃានៈ ។ គន្ធៈ ហៅថាគន្ធធាតុឬ ។ សីលគន្ធៈ សមាធិគន្ធៈ បញ្ញាគន្ធៈ ហៅថាគន្ធៈ មិនហៅគន្ធធាតុទេ ឯគន្ធធាតុ ហៅថាគន្ធៈផង ហៅថាគន្ធធាតុផង ។ គន្ធធាតុ ហៅថាគន្ធៈ ឬ ។ អើ ។ រស ហៅថារសធាតុឬ ។

ធម្មរសោ វិមុត្តិរសោ រសោ ច រសធាតុ រសធាតុ រសោ ចេវ រសធាតុ ច ។ រសធាតុ រសោតិ ។ អាមន្តា ។ ផោដ្ឋព្វោ ឃានសធិសោ ។ ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណធាតូតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណធាតុ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ សោតវិញ្ញាណំ ។ បេ ។ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ ។ មនោ មនោធាតូតិ ។ មនោធាតុំ ឋបេត្វា អវសេសោ មនោ មនោ ច មនោធាតុ មនោធាតុ មនោ ចេវ មនោធាតុ ច ។ មនោធាតុ មនោតិ ។ អាមន្តា ។ មនោវិញ្ញាណំ មនោវិញ្ញាណធាតូតិ ។ អាមន្តា ។ មនោវិញ្ញាណធាតុ មនោវិញ្ញាណន្តិ ។ អាមន្តា ។ ធម្មោ ធម្មធាតូតិ ។ ធម្មធាតុំ ឋបេត្វា អវសេសោ ធម្មោ ធម្មោ ច ធម្មធាតុ ធម្មធាតុ ធម្មោ ចេវ ធម្មធាតុ ច ។ ធម្មធាតុ ធម្មោតិ ។ អាមន្តា ។

(១១) ន ចក្ខុ ន ចក្ខុធាតូតិ ។ អាមន្តា ។ ន

អត្ថរស ធម្មរស វិមុត្តិរស ហៅថារស មិនហៅថារសធាតុទេ ឯរសធាតុ ហៅថារសផង ហៅថារសធាតុផង ។ រសធាតុ ហៅថារសឬ ។ អើ ។ ផោដ្ឋព្វៈ ដូចគ្នានឹងឃានៈ ។ ចក្ខុវិញ្ញាណ ហៅថាចក្ខុវិញ្ញាណធាតុ ឬ ។ អើ ។ ចក្ខុវិញ្ញាណធាតុ ហៅថាចក្ខុវិញ្ញាណឬ ។ អើ ។ សោតវិញ្ញាណ ។ បេ ។ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ។ មនៈ ហៅថាមនោធាតុឬ ។ មនៈដ៏សេស វៀរលែងមនោធាតុចេញ ហៅថាមនៈ មិនហៅថាមនោធាតុទេ ឯមនោធាតុ ហៅថាមនៈផង ហៅថាមនោធាតុផង ។ មនោធាតុ ហៅថាមនៈឬ ។ អើ ។ មនោវិញ្ញាណ ហៅថាមនោវិញ្ញាណធាតុឬ ។ អើ ។ មនោវិញ្ញាណធាតុ ហៅថាមនោវិញ្ញាណឬ ។ អើ ។ ធម៌ ហៅថាធម្មធាតុឬ ។ ធម៌ដ៏សេស វៀរលែងធម្មធាតុចេញ ហៅថាធម៌ មិនហៅថាធម្មធាតុទេ ឯធម្មធាតុ ហៅថាធម៌ផង ហៅថាធម្មធាតុផង ។ ធម្មធាតុ ហៅថាធម៌ឬ ។ អើ ។

(១១) មិនមែនចក្ខុ មិនហៅថាចក្ខុធាតុ ឬ ។ អើ ។ មិនមែន

ធាតុយមកេ បណ្ណត្តិវារស្ស និទ្ទេសោ

ចក្ខុធាតុ ន ចក្ខូតិ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ន ចក្ខុ-
ធាតុ ចក្ខុ ចក្ខុញ្ច ចក្ខុធាតុញ្ច ឋបេត្វា អវសេសំ ន
ចេវ ចក្ខុ ន ច ចក្ខុធាតុ ។ ន សោតំ ន សោតធា-
តូតិ ។ អាមន្តា ។ ន សោតធាតុ ន សោតន្តិ ។
ទិព្វសោតំ តណ្ហាសោតំ ន សោតធាតុ សោតំ
សោតញ្ច សោតធាតុញ្ច ឋបេត្វា អវសេសំ ន ចេវ
សោតំ ន ច សោតធាតុ ។ ន ឃានំ ន ឃានធា-
តូតិ ។ អាមន្តា ។ ន ឃានធាតុ ន ឃានន្តិ ។ អា-
មន្តា ។ យំ សង្ខិត្តំ ឧភតោ អាមន្តា ។ ន ជិវ្ហា
។ បេ ។ ន កាយោ ន កាយធាតូតិ ។ អាមន្តា ។
ន កាយធាតុ ន កាយោតិ ។ កាយធាតុំ
ឋបេត្វា អវសេសោ កាយោ ន កាយធាតុ
កាយោ កាយញ្ច កាយធាតុញ្ច ឋបេត្វា អវសេ-
សោ ន ចេវ កាយោ ន ច កាយធាតុ ។ ន
រូបំ ន រូបធាតូតិ ។ អាមន្តា ។ ន រូបធាតុ ន
រូបន្តិ ។ រូបធាតុំ ឋបេត្វា អវសេសំ រូបំ ន រូបធាតុ

ចក្ខុធាតុ មិនហៅថាចក្ខុឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ មិនហៅថាចក្ខុធាតុទេ ហៅថាចក្ខុ ធម្មជាតដ៏សេស វៀរលែងចក្ខុនិងចក្ខុធាតុចេញ មិនហៅថាចក្ខុផង មិនហៅថាចក្ខុធាតុផង ។ មិនមែនសោតៈ មិនហៅថាសោតធាតុឬ ។ អើ ។ មិនមែនសោតធាតុ មិនហៅថាសោតៈឬ ។ ទិព្វសោតៈ តណ្ហាសោតៈ មិនហៅថាសោតធាតុទេ ហៅថាសោតៈ ធម្មជាត ដ៏សេស វៀរលែងសោតៈ និងសោតធាតុចេញ មិនហៅថាសោតៈផង មិនហៅថាសោតធាតុផង ។ មិនមែនឃានៈ មិនហៅថាឃានធាតុឬ ។ អើ ។ មិនមែនឃានធាតុ មិនហៅថាឃានៈឬ ។ អើ ។ ពាក្យណាដែលលោកបំប្រួញហើយ (ពាក្យនោះ) មានអាមន្តា ពីរលើក ។ មិនមែនជិវ្ហា ។ បេ ។ មិនមែនកាយ មិនហៅថាកាយធាតុឬ ។ អើ ។ មិនមែនកាយធាតុ មិនហៅថាកាយឬ ។ កាយដ៏សេស វៀរលែងកាយធាតុចេញ មិនហៅថាកាយធាតុទេ ហៅថាកាយ ឯសភាវៈដ៏សេស វៀរលែងកាយនិងកាយធាតុចេញ មិនហៅថាកាយផង មិនហៅថាកាយធាតុផង ។ មិនមែនរូប មិនហៅថារូបធាតុឬ ។ អើ ។ មិនមែនរូបធាតុ មិនហៅថារូបឬ ។ រូបដ៏សេស វៀរលែងរូបធាតុចេញ មិនហៅថារូបធាតុទេ

រូបំ រូបញ្ច រូបធាតុញ្ច ឋបេត្វា អវសេសំ ន ចេវ រូបំ ន ច រូបធាតុ ។ ន សទ្ទោ ។ បេ ។ ន គន្ធោ ន គន្ធធាតូតិ ។ អាមន្តា ។ ន គន្ធធាតុ ន គន្ធោតិ ។ សីលគន្ធោ សមាធិគន្ធោ បញ្ញាគន្ធោ ន គន្ធធាតុ គន្ធោ គន្ធញ្ច គន្ធធាតុញ្ច ឋបេត្វា អវសេសោ ន ចេវ គន្ធោ ន ច គន្ធធាតុ ។ ន រសោ ន រសធាតូតិ ។ អាមន្តា ។ ន រសធាតុ ន រសោតិ ។ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ន រសធាតុ រសោ រសញ្ច រសធាតុញ្ច ឋបេត្វា អវសេសោ ន ចេវ រសោ ន ច រសធាតុ ។ ន ផោដ្ឋព្វោ ។ បេ ។ ន ចក្ខុវិញ្ញាណំ ន ចក្ខុវិញ្ញាណធាតូតិ ។ អាមន្តា ។ ន ចក្ខុវិញ្ញាណធាតុ ន ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ន សោតវិញ្ញាណំ ន ឃានវិញ្ញាណំ ន ជិវ្ហាវិញ្ញាណំ ន កាយវិញ្ញាណំ ។ ន មនោ ន មនោធាតូតិ ។ អាមន្តា ។ ន មនោធាតុ ន មនោតិ ។ មនោធាតុំ ឋបេត្វា អវសេសោ មនោ ន មនោធាតុ មនោ មនញ្ច មនោធាតុញ្ច ឋបេត្វា អវសេសោ ន ចេវ មនោ ន ច មនោធាតុ ។ ន មនោវិញ្ញាណំ

ហៅថារូប ឯធម្មជាត ដ៏សេស វៀរលែងរូប និងរូបធាតុចេញ មិនហៅថារូបផង មិនហៅថារូបធាតុផង ។ មិនមែនសទ្ទៈ ។ បេ ។ មិនមែនគន្ធៈ មិនហៅថាគន្ធធាតុឬ ។ អើ ។ មិនមែនគន្ធធាតុ មិនហៅថាគន្ធៈឬ ។ សីលគន្ធៈ សមាធិគន្ធៈ បញ្ញាគន្ធៈ មិនហៅថាគន្ធធាតុទេ ហៅថាគន្ធៈ ឯសភាវៈដ៏សេស វៀរលែងគន្ធៈ និងគន្ធធាតុចេញ មិនហៅថាគន្ធៈផង មិនហៅថាគន្ធធាតុផង ។ មិនមែនរសៈ មិនហៅថារសធាតុឬ ។ អើ ។ មិនមែនរសធាតុ មិនហៅថារសៈឬ ។ អត្ថរស ធម្មរស វិមុត្តិរស មិនហៅថារសធាតុទេ ហៅថារសៈ ឯសភាវៈដ៏សេស វៀរលែងរសៈ និងរសធាតុចេញ មិនហៅថារសៈផង មិនហៅថារសធាតុផង មិនមែនផោដ្ឋព្វៈ ។ បេ ។ មិនមែនចក្ខុវិញ្ញាណ មិនហៅថាចក្ខុវិញ្ញាណធាតុ ឬ ។ អើ ។ មិនមែនចក្ខុវិញ្ញាណធាតុ មិនហៅថាចក្ខុវិញ្ញាណ ឬ ។ អើ ។ មិនមែនសោតវិញ្ញាណ មិនមែនឃានវិញ្ញាណ មិនមែនជិវ្ហាវិញ្ញាណ មិនមែនកាយវិញ្ញាណ ។ មិនមែនមនៈ មិនហៅថាមនោធាតុឬ ។ អើ ។ មិនមែនមនោធាតុ មិនហៅថាមនៈឬ ។ មនៈដ៏សេស វៀរលែងមនោធាតុចេញ មិនហៅថាមនោធាតុទេ ហៅថាមនៈ ឯសភាវៈដ៏សេស វៀរលែងមនៈ និងមនោធាតុចេញ មិនហៅថាមនៈផង មិនហៅថាមនោធាតុផង ។ មិនមែនមនោវិញ្ញាណ

ន មនោវិញ្ញាណធាតូតិ ។ អាមន្តា ។ ន មនោ-
វិញ្ញាណធាតុ ន មនោវិញ្ញាណន្តិ ។ អាមន្តា ។ ន
ធម្មោ ន ធម្មធាតូតិ ។ អាមន្តា ។ ន ធម្មធាតុ
ន ធម្មោតិ ។ ធម្មធាតុំ ឋបេត្វា អវសេសា ធម្មោ
ន ធម្មធាតុ ធម្មោ ធម្មញ្ច ធម្មធាតុញ្ច ឋបេត្វា
អវសេសា ន ចេវ ធម្មោ ន ច ធម្មធាតុ ។

(១៦) ចក្ខុ ចក្ខុធាតូតិ ។ ទិព្វចក្ខុ បញ្ញា-
ចក្ខុ ចក្ខុ ន ចក្ខុធាតុ ចក្ខុធាតុ ចក្ខុ ចេវ
ចក្ខុធាតុ ច ។ ធាតូ សោតធាតូតិ ។ សោតធាតុ
ធាតុ ចេវ សោតធាតុ ច អវសេសា ធាតូ ធាតូ
ន សោតធាតុ ។ ចក្ខុ ចក្ខុធាតូតិ ។ ទិព្វចក្ខុ
បញ្ញាចក្ខុ ចក្ខុ ន ចក្ខុធាតុ ចក្ខុធាតុ ចក្ខុ ចេវ
ចក្ខុធាតុ ច ។ ធាតូ ឃានធាតុ ។ បេ ។ ធាតូ
ធម្មធាតូតិ ។ ធម្មធាតុ ធាតុ ចេវ ធម្មធាតុ ច
អវសេសា ធាតូ ធាតូ ន ធម្មធាតុ ។ យថា អាយ-
តនយមកេ បណ្ណត្តិ ឯវំ ធាតុយមកេបិ បណ្ណត្តិ ។
ចក្កំ ពន្ធិតព្វំ ។

ធាតុយមកៈ បណ្ណត្តិវារៈ និទ្ទេស

មិនហៅថា មនោវិញ្ញាណធាតុឬ ។ អើ ។ មិនមែនមនោវិញ្ញាណធាតុ មិនហៅថា មនោវិញ្ញាណ ឬ ។ អើ ។ មិនមែនធម៌ មិនហៅថា ធម្មធាតុឬ ។ អើ ។ មិនមែនធម្មធាតុ មិនហៅថាធម៌ឬ ។ ធម៌ដ៏សេស វៀរលែងធម្មធាតុចេញ មិនហៅថាធម្មធាតុទេ ហៅថាធម៌ ឯសភាវៈ ដ៏សេស វៀរលែងធម៌ និងធម្មធាតុចេញ មិនហៅថាធម៌ផង មិនហៅ ថាធម្មធាតុផង ។

(១៦) ចក្ខុ ហៅថាចក្ខុធាតុឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ហៅថា ចក្ខុ មិនហៅថាចក្ខុធាតុទេ ឯចក្ខុធាតុ ហៅថាចក្ខុផង ហៅថាចក្ខុ-ធាតុផង ។ ធាតុទាំងឡាយ ហៅថាសោតធាតុឬ ។ សោតធាតុ ហៅថាធាតុផង ហៅថាសោតធាតុផង ពួកធាតុដ៏សេស ហៅថាធាតុ មិនហៅថាសោតធាតុទេ ។ ចក្ខុ ហៅថាចក្ខុធាតុឬ ។ ទិព្វចក្ខុ បញ្ញា-ចក្ខុ ហៅថាចក្ខុ មិនហៅថាចក្ខុធាតុទេ ឯចក្ខុធាតុ ហៅថាចក្ខុផង ហៅថាចក្ខុធាតុផង ។ ធាតុទាំងឡាយ ហៅថាឃានធាតុ ។ បេ ។ ធាតុទាំងឡាយ ហៅថាធម្មធាតុឬ ។ ធម្មធាតុ ហៅថាធាតុផង ហៅ ថាធម្មធាតុផង ពួកធាតុដ៏សេស ហៅថាធាតុ មិនហៅថាធម្មធាតុទេ ។ បណ្ណត្តិ ក្នុងអាយតនយមកៈ យ៉ាងណា បណ្ណត្តិ ក្នុងធាតុយមកៈ ក៏ យ៉ាងនោះ ។ ចក្រ បណ្ណត្តិគប្បីចង ។

(១៣) ន ចក្ខុ ន ចក្ខុធាតូតិ ។ អាមន្តា ។ ន ធាតូ ន សោតធាតូតិ ។ អាមន្តា ។ ន ចក្ខុ ន ចក្ខុធាតូតិ ។ អាមន្តា ។ ន ធាតូ ន ឃានធាតុ ។ បេ ។ ន ធាតូ ន ធម្មធាតូតិ ។ អាមន្តា ។ ចក្កំ ពន្ធិតព្វំ ។ សព្វេ អាមន្តា ឧភតោបិ សេសេបិ ។

(១៤) ចក្ខុ ធាតូតិ ។ អាមន្តា ។ ធាតូ ចក្ខុធាតូតិ ។ ចក្ខុធាតុ ធាតុ ចេវ ចក្ខុធាតុ ច អវសេសា ធាតូ ធាតូ ន ចក្ខុធាតុ ។ សោតំ ធាតូតិ ។ អាមន្តា ។ បេ ។ ឃានំ ជិវ្ហា កាយោ រូបំ សទ្ទោ គន្ធោ រសោ ផោដ្ឋព្វោ ។ ចក្ខុវិញ្ញាណំ ធាតូតិ ។ អាមន្តា ។ ធាតូ ចក្ខុវិញ្ញាណធាតូតិ ។ ចក្ខុវិញ្ញាណធាតុ ធាតុ ចេវ ចក្ខុវិញ្ញាណធាតុ ច អវសេសា ធាតូ ធាតូ ន ចក្ខុវិញ្ញាណធាតុ ។ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ ។ មនោ ធាតូតិ ។ អាមន្តា ។ ធាតូ មនោធាតូតិ ។ មនោធាតុ ធាតុ ចេវ មនោធាតុ ច អវសេសា ធាតូ ធាតូ ន មនោធាតុ ។

(១៣) មិនមែនចក្ខុ មិនហៅថាចក្ខុធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថាសោតធាតុឬ ។ អើ ។ មិនមែនចក្ខុ មិនហៅថាចក្ខុធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថាឃានៈ-ធាតុ ។ បេ ។ មិនមែនធាតុទាំងឡាយ មិនហៅថាធម្មធាតុឬ ។ អើ ។ ចក្រ បណ្ឌិតគប្បីចង ។ អាមន្តា ទាំងអស់ មានពីរក៏មាន មានសេសក៏មាន ។

(១៤) ចក្ខុ ហៅថាធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថាចក្ខុធាតុឬ ។ ចក្ខុធាតុ ហៅថាធាតុផង ហៅថាចក្ខុធាតុផង ពួកធាតុដ៏សេស ហៅថាធាតុ មិនហៅថាចក្ខុធាតុទេ ។ សោតៈ ហៅថាធាតុឬ ។ អើ ។ បេ ។ ឃានៈ ជិវ្ហា កាយ រូប សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ។ ចក្ខុវិញ្ញាណ ហៅថាធាតុឬ ។ អើ ។ ធាតុទាំង-ឡាយ ហៅថាចក្ខុវិញ្ញាណធាតុឬ ។ ចក្ខុវិញ្ញាណធាតុ ហៅថាធាតុផង ហៅថាចក្ខុវិញ្ញាណធាតុផង ពួកធាតុដ៏សេស ហៅថាធាតុ មិនហៅថាចក្ខុវិញ្ញាណធាតុទេ ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហា-វិញ្ញាណ កាយវិញ្ញាណ ។ មនៈ ហៅថាធាតុឬ ។ អើ ។ ធាតុទាំង-ឡាយ ហៅថាមនោធាតុឬ ។ មនោធាតុ ហៅថាធាតុផង ហៅថាម-នោធាតុផង ពួកធាតុដ៏សេស ហៅថាធាតុ មិនហៅថាមនោធាតុទេ ។

ធាតុយមកេ បណ្ណត្តិវារស្ស និទ្ទេសោ

មនោវិញ្ញាណំ ធាតូតិ ។ អាមន្តា ។ ធាតូ មនោវិញ្ញាណធាតូតិ ។ មនោវិញ្ញាណធាតុ ធាតុ ចេវ មនោវិញ្ញាណធាតុ ច អវសេសា ធាតូ ធាតូ ន មនោវិញ្ញាណធាតុ ។ ធម្មា ធាតូតិ ។ អាមន្តា ។ ធាតូ ធម្មធាតូតិ ។ ធម្មធាតុ ធាតុ ចេវ ធម្មធាតុ ច អវសេសា ធាតូ ធាតូ ន ធម្មធាតុ ។

(១៨) ន ចក្ខុ ន ធាតូតិ ។ ចក្ខុំ ឋបេត្វា អវសេសា ធាតូ ន ចក្ខុធាតុ ចក្ខុញ្ច ធាតុញ្ច ឋបេត្វា អវសេសា ន ចេវ ចក្ខុ ន ច ធាតុ ។ ន ធាតូ ន ចក្ខុធាតូតិ ។ អាមន្តា ។ ន សោតំ ន ធាតូតិ ។ សោតំ ឋបេត្វា ។ បេ ។ ឃានំ ឋបេត្វា ជិវ្ហំ ឋបេត្វា ។ បេ ។ ន កាយោ ន ធាតូតិ ។ អាមន្តា ។ ន ធាតូ ន កាយធាតូតិ ។ អាមន្តា ។ ន រូបំ ន ធាតូតិ ។ រូបំ ឋបេត្វា ។ បេ ។ សទ្ទំ គន្ធំ រសំ ផោដ្ឋព្វំ ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនំ មនោវិញ្ញាណំ ឋបេត្វា ។ បេ ។ ន ធម្មា ន ធាតូតិ ។ អាមន្តា ។ ន ធាតូ ន ធម្មធាតូតិ ។ អាមន្តា ។

មនោវិញ្ញាណ ហៅថាធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថាមនោវិញ្ញាណធាតុឬ ។ មនោវិញ្ញាណធាតុ ហៅថាធាតុផង ហៅថាមនោវិញ្ញាណធាតុផង ពួកធាតុ ដ៏សេស ហៅថាធាតុ មិនហៅថាមនោវិញ្ញាណធាតុទេ ។ ធម៌ ហៅធាតុឬ ។ អើ ។ ធាតុទាំងឡាយហៅថាធម្មធាតុឬ ។ ធម្មធាតុ ហៅថាធាតុផង ហៅថាធម្មធាតុផង ពួកធាតុ ដ៏សេស ហៅថាធាតុ មិនហៅថាធម្មធាតុទេ ។

(១៥) មិនមែនចក្ខុ មិនហៅថាធាតុឬ ។ ពួកធាតុដ៏សេស វៀរលែងចក្ខុចេញ មិនហៅថាចក្ខុធាតុ ឯធម្មជាតិដ៏សេស វៀរលែងចក្ខុនិងធាតុចេញ មិនហៅថាចក្ខុផង មិនហៅថាធាតុផង ។ មិនមែនធាតុទាំងឡាយ មិនហៅថាចក្ខុធាតុឬ ។ អើ ។ មិនមែនសោតៈ មិនហៅថាធាតុឬ ។ (ពួកធាតុដ៏សេស) វៀរលែងសោតៈចេញ ។ បេ ។ វៀរលែងឃានៈ វៀរលែងជិវ្ហាចេញ ។ បេ ។ មិនមែនកាយ មិនហៅថាធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថាកាយធាតុឬ ។ អើ ។ មិនមែនរូប មិនហៅថាធាតុឬ ។ (ពួកធាតុដ៏សេស) វៀរលែងរូបចេញ ។ បេ ។ វៀរលែង សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ចក្ខុ-វិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនៈ មនោវិញ្ញាណចេញ ។ បេ ។ មិនមែនធម៌ មិនហៅថាធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថាធម្មធាតុឬ ។ អើ ។

(១៦) ចក្ខុ ធាតូតិ ។ អាមន្តា ។ ធាតូ សោតធាតូតិ ។ សោតធាតុ ធាតុ ចេវ សោតធាតុ ច អវសេសា ធាតូ ធាតូ ន សោតធាតុ ។ ចក្ខុ ធាតូតិ ។ អាមន្តា ។ ធាតូ ឃានធាតុ ។ បេ ។ ធាតូ ធម្មធាតូតិ ។ ធម្មធាតុ ធាតុ ចេវ ធម្មធាតុ ច អវសេសា ធាតូ ធាតូ ន ធម្មធាតុ ។ ចក្កំ ពន្ធិតព្វំ ។

(១៧) ន ចក្ខុ ន ធាតូតិ ។ ចក្ខុំ ឋបេត្វា អវសេសា ធាតូ ន ចក្ខុធាតុ ចក្ខុញ្ច ធាតុញ្ច ឋបេត្វា អវសេសា ន ចេវ ចក្ខុ ន ច ធាតុ ។ ន ធាតុ ន សោតធាតូតិ ។ អាមន្តា ។ ន ចក្ខុ ន ធាតូតិ ។ ចក្ខុំ ឋបេត្វា អវសេសា ន ចក្ខុ ធាតុ ចក្ខុញ្ច ធាតុញ្ច ឋបេត្វា អវសេសា ន ចេវ ចក្ខុ ន ច ធាតុ ។ ន ធាតុ ន ឃានធាតុ ។ បេ ។ ន ធាតូ ន ធម្មធាតូតិ ។ អាមន្តា ។ បេ ។ ន ធម្មោ ន ធាតូតិ ។ អាមន្តា ។ ន ធាតុ ន សោតធាតុ ។ បេ ។ ន ធាតូ ន មនោវិញ្ញាណធាតូតិ ។ អាមន្តា ។ ចក្កំ ពន្ធិតព្វំ ។

(១៦) ចក្ខុ ហៅថាធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថាសោតធាតុឬ ។ សោតធាតុ ហៅថាធាតុផង ហៅថាសោតធាតុផង ពួកធាតុដ៏សេស ហៅថាធាតុ មិនហៅថាសោតធាតុទេ ។ ចក្ខុ ហៅថាធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថាឃានធាតុ ។ បេ ។ ធាតុទាំងឡាយ ហៅថាធម្មធាតុឬ ។ ធម្មធាតុ ហៅថាធាតុផង ហៅថាធម្មធាតុផង ពួកធាតុដ៏សេស ហៅថាធាតុ មិនហៅថាធាតុទេ ។ ចក្របណ្ឌិតគប្បីចង ។

(១៧) មិនមែនចក្ខុ មិនហៅថាធាតុឬ ។ ពួកធាតុដ៏សេស វៀរលែងចក្ខុចេញ មិនហៅថាចក្ខុធាតុ ឯធម្មជាតិដ៏សេស វៀរលែងចក្ខុ និងធាតុចេញ មិនហៅថាចក្ខុផង មិនហៅថាធាតុផង ។ មិនមែនធាតុ មិនហៅថាសោតធាតុឬ ។ អើ ។ មិនមែនចក្ខុ មិនហៅថាធាតុឬ ។ ពួកធាតុដ៏សេស វៀរលែងចក្ខុចេញ មិនហៅថាចក្ខុ ហៅថាធាតុ ឯធម្មជាតិដ៏សេស វៀរលែងចក្ខុ និងធាតុចេញ មិនហៅថាចក្ខុផង មិនហៅថាធាតុផង ។ មិនមែនធាតុទាំងឡាយ មិនហៅថាឃានធាតុ ។ បេ ។ មិនមែនពួកធាតុ មិនហៅថាធម្មធាតុឬ ។ អើ ។ បេ ។ មិនមែនធម៌ មិនហៅថាធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថាសោតធាតុ ។ បេ ។ មិនមែនធាតុទាំង-ឡាយ មិនហៅថាមនោវិញ្ញាណធាតុឬ ។ អើ ។ ចក្របណ្ឌិតគប្បីចង ។

យថា អាយតនយមកស្ស បណ្ណត្តិ ឯវំ ធាតុយមកស្ស បណ្ណត្តិ វិត្ថារេតព្វា ។

បណ្ណត្តិវារោ ។

(១៨) យស្ស ចក្ខុធាតុ ឧប្បជ្ជតិ តស្ស សោតធាតុ ឧប្បជ្ជតីតិ ។ សចក្ខុកានំ អសោតកានំ ឧបបជ្ជន្តានំ តេសំ ចក្ខុធាតុ ឧប្បជ្ជតិ នោ ច តេសំ សោតធាតុ ឧប្បជ្ជតិ សចក្ខុកានំ សសោតកានំ ឧបបជ្ជន្តានំ តេសំ ចក្ខុធាតុ ច ឧប្បជ្ជតិ សោតធាតុ ច ឧប្បជ្ជតិ ។ យស្ស វា បន សោតធាតុ ឧប្បជ្ជតិ តស្ស ចក្ខុធាតុ ឧប្បជ្ជតីតិ ។ សសោតកានំ អចក្ខុកានំ ឧបបជ្ជន្តានំ តេសំ សោតធាតុ ឧប្បជ្ជតិ នោ ច តេសំ ចក្ខុធាតុ ឧប្បជ្ជតិ សសោតកានំ សចក្ខុកានំ ឧបបជ្ជន្តានំ តេសំ សោតធាតុ ច ឧប្បជ្ជតិ ចក្ខុធាតុ ច ឧប្បជ្ជតិ ។

(១៩) យស្ស ចក្ខុធាតុ ឧប្បជ្ជតិ តស្ស ឃានធាតុ ឧប្បជ្ជតីតិ ។ សចក្ខុកានំ អឃានកានំ

ធាតុយមកៈ បវត្តិវារៈ ឧប្បាទវារៈ

បណ្ណត្តិ នៃអាយតនយមកៈ យ៉ាងណា បណ្ណត្តិ នៃធាតុយមកៈ បណ្ឌិតគប្បីឱ្យពិស្តារ យ៉ាងនោះដែរ ។

ចប់បណ្ណត្តិវារៈ ។

(១៨) ចក្ខុធាតុ របស់សត្វណា រមែងកើតឡើង សោតធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វ ដែលមានចក្ខុ មិនមានសោតៈ កាលកើតឡើង ចក្ខុធាតុ របស់សត្វទាំងនោះ រមែងកើតឡើង ឯសោតធាតុ របស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វ មានចក្ខុ មានសោតៈ កាលកើតឡើង ចក្ខុធាតុ របស់សត្វទាំងនោះ រមែងកើតឡើងផង សោតធាតុ រមែងកើតឡើងផង ។ មួយទៀត សោតធាតុ របស់សត្វណា រមែងកើតឡើង ចក្ខុធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វ មានសោតៈ មិនមានចក្ខុ កាលកើតឡើង សោតធាតុ របស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុ របស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វ មានសោតៈ មានចក្ខុ កាលកើតឡើង សោតធាតុ របស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។

(១៩) ចក្ខុធាតុ របស់សត្វណា រមែងកើតឡើង ឃានធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វ មានចក្ខុ មិនមានឃានៈ

ឧបបជ្ជន្តានំ តេសំ ចក្ខុធាតុ ឧប្បជ្ជតិ នោ ច តេសំ ឃានធាតុ ឧប្បជ្ជតិ សចក្ខុកានំ សឃានកានំ ឧបបជ្ជន្តានំ តេសំ ចក្ខុធាតុ ច ឧប្បជ្ជតិ ឃានធាតុ ច ឧប្បជ្ជតិ ។ យស្ស វា បន ឃានធាតុ ឧប្បជ្ជតិ តស្ស ចក្ខុធាតុ ឧប្បជ្ជតីតិ ។ សឃានកានំ អចក្ខុកានំ ឧបបជ្ជន្តានំ តេសំ ឃានធាតុ ឧប្បជ្ជតិ នោ ច តេសំ ចក្ខុធាតុ ឧប្បជ្ជតិ សឃានកានំ សចក្ខុកានំ ឧបបជ្ជន្តានំ តេសំ ឃានធាតុ ច ឧប្បជ្ជតិ ចក្ខុធាតុ ច ឧប្បជ្ជតិ ។

(២០) យស្ស ចក្ខុធាតុ ឧប្បជ្ជតិ តស្ស រូបធាតុ ឧប្បជ្ជតីតិ ។ អាមន្តា ។ យស្ស វា បន រូបធាតុ ឧប្បជ្ជតិ តស្ស ចក្ខុធាតុ ឧប្បជ្ជតីតិ ។ សរូបកានំ អចក្ខុកានំ ឧបបជ្ជន្តានំ តេសំ រូបធាតុ ឧប្បជ្ជតិ នោ ច តេសំ ចក្ខុធាតុ ឧប្បជ្ជតិ សរូបកានំ សចក្ខុកានំ ឧបបជ្ជន្តានំ តេសំ រូបធាតុ ច ឧប្បជ្ជតិ ចក្ខុធាតុ ច ឧប្បជ្ជតិ ។

កាលកើតឡើង ចក្ខុធាតុ របស់សត្វទាំងនោះ រមែងកើតឡើង ឯឃានធាតុ របស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វ មានចក្ខុ មានឃានៈ កាលកើតឡើង ចក្ខុធាតុ របស់សត្វទាំងនោះ រមែងកើតឡើងផង ឃានធាតុ រមែងកើតឡើងផង ។ មួយទៀត ឃានធាតុ របស់សត្វណា រមែងកើតឡើង ចក្ខុធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វ មានឃានៈ មិនមានចក្ខុ កាលកើតឡើង ឃានធាតុ របស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុ របស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វ មានឃានៈ មានចក្ខុ កាលកើតឡើង ឃានធាតុ របស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។

(២០) ចក្ខុធាតុ របស់សត្វណា រមែងកើតឡើង រូបធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ អើ ។ មួយទៀត រូបធាតុ របស់សត្វណា រមែងកើតឡើង ចក្ខុធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វ មានរូប មិនមានចក្ខុ កាលកើតឡើង រូបធាតុ របស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុ របស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វ មានរូប មានចក្ខុ កាលកើតឡើង រូបធាតុ របស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។

ធាតុយមកេ បវត្តិវារស្ស ឧប្បាទវារោ

(២១) យស្ស ចក្ខុធាតុ ឧប្បជ្ជតិ តស្ស មនោវិញ្ញាណធាតុ ឧប្បជ្ជតីតិ ។ អាមន្តា ។ យស្ស វា បន មនោវិញ្ញាណធាតុ ឧប្បជ្ជតិ តស្ស ចក្ខុធាតុ ឧប្បជ្ជតីតិ ។ សចិត្តកានំ អចក្ខុកានំ ឧបបជ្ជន្តានំ តេសំ មនោវិញ្ញាណធាតុ ឧប្បជ្ជតិ នោ ច តេសំ ចក្ខុធាតុ ឧប្បជ្ជតិ សចិត្តកានំ សចក្ខុកានំ ឧបបជ្ជន្តានំ តេសំ មនោវិញ្ញាណធាតុ ច ឧប្បជ្ជតិ ចក្ខុធាតុ ច ឧប្បជ្ជតិ ។

(២២) យស្ស ចក្ខុធាតុ ឧប្បជ្ជតិ តស្ស ធម្មធាតុ ឧប្បជ្ជតីតិ ។ អាមន្តា ។ យស្ស វា បន ធម្មធាតុ ឧប្បជ្ជតិ តស្ស ចក្ខុធាតុ ឧប្បជ្ជតីតិ ។ អចក្ខុកានំ ឧបបជ្ជន្តានំ តេសំ ធម្មធាតុ ឧប្បជ្ជតិ នោ ច តេសំ ចក្ខុធាតុ ឧប្បជ្ជតិ សចក្ខុកានំ ឧបបជ្ជន្តានំ តេសំ ធម្មធាតុ ច ឧប្បជ្ជតិ ចក្ខុធាតុ ច ឧប្បជ្ជតិ ។ យថា អាយតនយមកំ វិភត្តំ ឯវំ ធាតុយមកម្បិ វិភជិតព្វំ សទិសំ កាតព្វំ ។

(២១) ចក្ខុធាតុ របស់សត្វណា រមែងកើតឡើង មនោវិញ្ញាណធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ អើ ។ មួយទៀត មនោវិញ្ញាណធាតុ របស់សត្វណា រមែងកើតឡើង ចក្ខុធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វ មានចិត្ត មិនមានចក្ខុ កាលកើតឡើង មនោវិញ្ញាណធាតុ របស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុ របស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វ មានចិត្ត មានចក្ខុ កាលកើតឡើង មនោវិញ្ញាណធាតុ របស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។

(២២) ចក្ខុធាតុ របស់សត្វណា រមែងកើតឡើង ធម្មធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ អើ ។ មួយទៀត ធម្មធាតុ របស់សត្វណា រមែងកើតឡើង ចក្ខុធាតុ របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វ មិនមានចក្ខុ កាលកើតឡើង ធម្មធាតុ របស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុ របស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វមានចក្ខុ កាលកើតឡើង ធម្មធាតុ របស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។ អាយតនយមកៈ លោកចែកហើយ យ៉ាងណា ឯធាតុយមកៈ បណ្ឌិតគប្បីចែកធ្វើឲ្យដូច ៗ គ្នា យ៉ាងនោះដែរ ។

(២៣) យោ ចក្ខុធាតុំ បរិជានាតិ សោ សោតធាតុំ បរិជានាតីតិ ។ អាមន្តា ។ បេ ។

ធាតុយមកំ បរិបុណ្ណំ បេយ្យាលេន ។

ធាតុយមកំ និដ្ឋិតំ(១) ។

## សច្ចយមកំ បណ្ណត្តិវារោ

ចត្តារិ សច្ចានិ ទុក្ខសច្ចំ សមុទយសច្ចំ និរោធសច្ចំ មគ្គសច្ចំ ។

### ឧទ្ទេសវារោ

(២៤) ទុក្ខំ ទុក្ខសច្ចំ ទុក្ខសច្ចំ ទុក្ខំ ។ សមុទយោ សមុទយសច្ចំ សមុទយសច្ចំ សមុទយោ ។ និរោធោ និរោធសច្ចំ និរោធសច្ចំ និរោធោ ។ មគ្គោ មគ្គសច្ចំ មគ្គសច្ចំ មគ្គោ ។

(២៥) ន ទុក្ខំ ន ទុក្ខសច្ចំ ន ទុក្ខសច្ចំ ន ទុក្ខំ ។ ន សមុទយោ ន សមុទយសច្ចំ ន សមុទយសច្ចំ ន សមុទយោ ។ ន និរោធោ ន និរោធសច្ចំ ន និរោធសច្ចំ ន និរោធោ ។ ន មគ្គោ ន មគ្គសច្ចំ ន មគ្គសច្ចំ ន មគ្គោ ។

---

១ ឱ. ចតុត្ថំ យមកវារំ និដ្ឋិតន្តិ ទិស្សន្តិ ។ ម. ចតុត្ថោ យមកវារោ និដ្ឋិតោតិ ទិស្សន្តិ ។

(២៣) បុគ្គលណា កំណត់ដឹងនូវចក្ខុធាតុ បុគ្គលនោះ កំណត់ដឹងនូវសោតធាតុឬ ។ អើ ។ បេ ។

ចប់ ធាតុយមកៈ បរិបូណ៌ដោយបេយ្យាល ។

ចប់ ធាតុយមកៈ ។

# សច្ចយមកៈ បណ្ណត្តិវារៈ

សច្ចៈ ៤ គឺ ទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ។

## ឧទ្ទេសវារៈ

(២៤) ទុក្ខៈ ហៅថាទុក្ខសច្ច ទុក្ខសច្ច ហៅថាទុក្ខៈ ។ សមុទយៈ ហៅថាសមុទយសច្ច សមុទយសច្ច ហៅថាសមុទយៈ ។ និរោធៈ ហៅថានិរោធសច្ច និរោធសច្ច ហៅថានិរោធៈ ។ មគ្គៈ ហៅថាមគ្គសច្ច មគ្គសច្ច ហៅថាមគ្គៈ ។

(២៥) មិនមែនទុក្ខៈ មិនហៅថាទុក្ខសច្ច មិនមែនទុក្ខសច្ច មិនហៅថាទុក្ខៈ ។ មិនមែនសមុទយៈ មិនហៅថាសមុទយសច្ច មិនមែនសមុទយសច្ច មិនហៅថាសមុទយៈ ។ មិនមែននិរោធៈ មិនហៅថានិរោធសច្ច មិនមែននិរោធសច្ច មិនហៅថានិរោធៈ ។ មិនមែនមគ្គៈ មិនហៅថា មគ្គសច្ច មិនមែនមគ្គសច្ច មិនហៅថាមគ្គៈ ។

## សច្ចយមកេ បណ្ណត្តិវារស្ស ឧទ្ទេសោ

(២៦) ទុក្ខំ ទុក្ខសច្ចំ សច្ចា សមុទយសច្ចំ ។ ទុក្ខំ ទុក្ខសច្ចំ សច្ចា និរោធសច្ចំ ។ ទុក្ខំ ទុក្ខសច្ចំ សច្ចា មគ្គសច្ចំ ។ សមុទយោ សមុទយសច្ចំ សច្ចា ទុក្ខសច្ចំ ។ សមុទយោ សមុទយសច្ចំ សច្ចា និរោធសច្ចំ ។ សមុទយោ សមុទយសច្ចំ សច្ចា មគ្គសច្ចំ ។ និរោធោ និរោធសច្ចំ សច្ចា ទុក្ខសច្ចំ ។ និរោធោ និរោធសច្ចំ សច្ចា សមុទយសច្ចំ ។ និរោធោ និរោធសច្ចំ សច្ចា មគ្គសច្ចំ ។ មគ្គោ មគ្គសច្ចំ សច្ចា ទុក្ខសច្ចំ ។ មគ្គោ មគ្គសច្ចំ សច្ចា សមុទយសច្ចំ ។ មគ្គោ មគ្គសច្ចំ សច្ចា និរោធសច្ចំ ។

(២៧) ន ទុក្ខំ ន ទុក្ខសច្ចំ ន សច្ចា ន សមុទយសច្ចំ ។ ន ទុក្ខំ ន ទុក្ខសច្ចំ ន សច្ចា ន និរោធសច្ចំ ។ ន ទុក្ខំ ន ទុក្ខសច្ចំ ន សច្ចា ន មគ្គសច្ចំ ។ ន សមុទយោ ន សមុទយសច្ចំ ន សច្ចា ន ទុក្ខសច្ចំ ។ ន សមុទយោ ន សមុទយសច្ចំ ន

សច្ចយមក: បណ្ណត្តិវារ: ឧទ្ទេស

(២៦) ទុក្ខ: ហៅថាទុក្ខសច្ច សច្ច:ទាំងឡាយ ហៅថាសមុទយសច្ច ។ ទុក្ខ: ហៅថាទុក្ខសច្ច សច្ច:ទាំងឡាយ ហៅថានិរោធសច្ច ។ ទុក្ខ: ហៅថាទុក្ខសច្ច សច្ច:ទាំងឡាយ ហៅថាមគ្គសច្ច ។ សមុទយ: ហៅថា សមុទយសច្ច សច្ច:ទាំងឡាយ ហៅថាទុក្ខសច្ច ។ សមុទយ: ហៅថាសមុទយសច្ច សច្ច:ទាំងឡាយ ហៅថានិរោធសច្ច ។ សមុទយ: ហៅថាសមុទយសច្ច សច្ច:ទាំងឡាយ ហៅថាមគ្គសច្ច ។ និរោធ: ហៅថានិរោធសច្ច សច្ច:ទាំងឡាយ ហៅថាទុក្ខសច្ច ។ និរោធ: ហៅថា និរោធសច្ច សច្ច:ទាំងឡាយ ហៅថាសមុទយសច្ច ។ និរោធ: ហៅថា និរោធសច្ច សច្ច:ទាំងឡាយ ហៅថាមគ្គសច្ច ។ មគ្គ: ហៅថាមគ្គសច្ច សច្ច:ទាំងឡាយ ហៅថាទុក្ខសច្ច ។ មគ្គ: ហៅថាមគ្គសច្ច សច្ច:ទាំងឡាយ ហៅថាសមុទយសច្ច ។ មគ្គ: ហៅថាមគ្គសច្ច សច្ច:ទាំងឡាយ ហៅថានិរោធសច្ច ។

(២៧) មិនមែនទុក្ខ: មិនហៅថាទុក្ខសច្ច មិនមែនសច្ច:ទាំងឡាយ មិនហៅថាសមុទយសច្ច ។ មិនមែនទុក្ខ: មិនហៅថាទុក្ខសច្ច មិនមែនសច្ច:ទាំងឡាយ មិនហៅថានិរោធសច្ច ។ មិនមែនទុក្ខ: មិនហៅថាទុក្ខសច្ច មិនមែនសច្ច:ទាំងឡាយ មិនហៅថាមគ្គសច្ច ។ មិនមែនសមុទយ: មិនហៅថាសមុទយសច្ច មិនមែនសច្ច:ទាំងឡាយ មិនហៅថាទុក្ខសច្ច ។ មិនមែនសមុទយ: មិនហៅថាសមុទយសច្ច មិនមែន

សច្ចា ន និរោធសច្ចំ ។ ន សមុទយោ ន សមុទយសច្ចំ ន សច្ចា ន មគ្គសច្ចំ ។ ន និរោធោ ន និរោធសច្ចំ ន សច្ចា ន ទុក្ខសច្ចំ ។ ន និរោធោ ន និរោធសច្ចំ ន សច្ចា ន សមុទយសច្ចំ ។ ន និរោធោ ន និរោធសច្ចំ ន សច្ចា ន មគ្គសច្ចំ ។ ន មគ្គោ ន មគ្គសច្ចំ ន សច្ចា ន ទុក្ខសច្ចំ ។ ន មគ្គោ ន មគ្គសច្ចំ ន សច្ចា ន សមុទយសច្ចំ ។ ន មគ្គោ ន មគ្គសច្ចំ ន សច្ចា ន និរោធសច្ចំ ។

(២៨) ទុក្ខំ សច្ចំ សច្ចា ទុក្ខំ ។ សមុទយោ សច្ចំ សច្ចា សមុទយោ ។ និរោធោ សច្ចំ សច្ចា និរោធោ ។ មគ្គោ សច្ចំ សច្ចា មគ្គោ ។

(២៩) ន ទុក្ខំ ន សច្ចំ ន សច្ចា ន ទុក្ខំ ។ ន សមុទយោ ន សច្ចំ ន សច្ចា ន សមុទយោ ។ ន និរោធោ ន សច្ចំ ន សច្ចា ន និរោធោ ។ ន មគ្គោ ន សច្ចំ ន សច្ចា ន មគ្គោ ។

សច្ចៈទាំងឡាយ មិនហៅថានិរោធសច្ច ។ មិនមែនសមុទយៈ មិនហៅថាសមុទយសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គសច្ច ។ មិនមែននិរោធៈ មិនហៅថានិរោធសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខសច្ច ។ មិនមែននិរោធៈ មិនហៅថានិរោធសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយសច្ច ។ មិនមែននិរោធៈ មិនហៅថានិរោធសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គសច្ច ។ មិនមែនមគ្គៈ មិនហៅថាមគ្គសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខសច្ច ។ មិនមែនមគ្គៈ មិនហៅថាមគ្គសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយសច្ច ។ មិនមែនមគ្គៈ មិនហៅថាមគ្គសច្ច មិនមែនសច្ចៈទាំង-ឡាយ មិនហៅថានិរោធសច្ច ។

(២៨) ទុក្ខៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថាទុក្ខៈ ។ សមុទយៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថាសមុទយៈ ។ និរោធៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថានិរោធៈ ។ មគ្គៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថាមគ្គៈ ។

(២៩) មិនមែនទុក្ខៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខៈ ។ មិនមែនសមុទយៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយៈ ។ មិនមែននិរោធៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថានិរោធៈ ។ មិនមែនមគ្គៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គៈ ។

សច្ចយមកេ បណ្ណត្តិវារស្ស ឧទ្ទេសោ

(៣០) ទុក្ខំ សច្ចំ សច្ចា សមុទយោ ។ ទុក្ខំ សច្ចំ សច្ចា និរោធោ ។ ទុក្ខំ សច្ចំ សច្ចា មគ្គោ ។ សមុទយោ សច្ចំ សច្ចា ទុក្ខំ ។ បេ ។ សច្ចា មគ្គោ ។ និរោធោ សច្ចំ សច្ចា ទុក្ខំ ។ បេ ។ សច្ចា មគ្គោ ។ មគ្គោ សច្ចំ សច្ចា ទុក្ខំ ។ មគ្គោ សច្ចំ សច្ចា សមុទយោ ។ មគ្គោ សច្ចំ សច្ចា និរោធោ ។

(៣១) ន ទុក្ខំ ន សច្ចំ ន សច្ចា ន សមុទយោ ។ ន ទុក្ខំ ន សច្ចំ ន សច្ចា ន និរោធោ ។ ន ទុក្ខំ ន សច្ចំ ន សច្ចា ន មគ្គោ ។ ន សមុទយោ ន សច្ចំ ន សច្ចា ន ទុក្ខំ ។ បេ ។ ន សច្ចា ន មគ្គោ ។ ន និរោធោ ន សច្ចំ ន សច្ចា ន ទុក្ខំ ។ បេ ។ ន សច្ចា ន មគ្គោ ។ ន មគ្គោ ន សច្ចំ ន សច្ចា ន ទុក្ខំ ។ ន មគ្គោ ន សច្ចំ ន សច្ចា ន សមុទយោ ។

សច្ចយមកៈ បណ្ណត្តិវារៈ ឧទ្ទេស

(៣០) ទុក្ខៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថាសមុទយៈ ។ ទុក្ខៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថានិរោធៈ ។ ទុក្ខៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថាមគ្គៈ ។ សមុទយៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថា ទុក្ខៈ ។ បេ ។ សច្ចៈទាំងឡាយ ហៅថាមគ្គៈ ។ និរោធៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថាទុក្ខៈ ។ បេ ។ សច្ចៈទាំង-ឡាយ ហៅថាមគ្គៈ ។ មគ្គៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថាទុក្ខៈ ។ មគ្គៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថាសមុទយៈ ។ មគ្គៈ ហៅថាសច្ចៈ សច្ចៈទាំងឡាយ ហៅថានិរោធៈ ។

(៣១) មិនមែនទុក្ខៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយៈ ។ មិនមែនទុក្ខៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំង-ឡាយ មិនហៅថានិរោធៈ ។ មិនមែនទុក្ខៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គៈ ។ មិនមែនសមុទយៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខៈ ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គៈ ។ មិនមែននិរោធៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខៈ ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គៈ ។ មិនមែនមគ្គៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខៈ ។ មិនមែនមគ្គៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយៈ ។

ន មគ្គោ ន សច្ចំ ន សច្ចា ន និរោធោ ។

ឧទ្ទេសវារោ ។

## និទ្ទេសវារោ

(៣២) ទុក្ខំ ទុក្ខសច្ចន្តិ ។ អាមន្តា ។ ទុក្ខសច្ចំ ទុក្ខន្តិ ។ កាយិកំ ទុក្ខំ ចេតសិកំ ទុក្ខំ ឋបេត្វា អវសេសំ ទុក្ខសច្ចំ ទុក្ខសច្ចំ ន ទុក្ខំ កាយិកំ ទុក្ខំ ចេតសិកំ ទុក្ខំ ទុក្ខញ្ចេវ ទុក្ខសច្ចញ្ច ។ សមុទយោ សមុទយសច្ចន្តិ ។ សមុទយសច្ចំ ឋបេត្វា អវសេសោ សមុទយោ សមុទយោ ន សមុទយសច្ចំ សមុទយសច្ចំ សមុទយោ ចេវ សមុទយសច្ចញ្ច ។ សមុទយសច្ចំ សមុទយោតិ ។ អាមន្តា ។ និរោធោ និរោធសច្ចន្តិ ។ និរោធសច្ចំ ឋបេត្វា អវសេសោ និរោធោ និរោធោ ន និរោធសច្ចំ និរោធសច្ចំ និរោធោ ចេវ និរោធសច្ចញ្ច ។ និរោធសច្ចំ និរោធោតិ ។ អាមន្តា ។ មគ្គោ មគ្គសច្ចន្តិ ។ មគ្គសច្ចំ ឋបេត្វា អវសេសោ មគ្គោ មគ្គោ ន មគ្គសច្ចំ មគ្គសច្ចំ មគ្គោ ចេវ មគ្គសច្ចញ្ច ។ មគ្គសច្ចំ មគ្គោតិ ។ អាមន្តា ។

មិនមែនមគ្គៈ មិនហៅថាសច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថានិរោធៈ ។

ចប់ ឧទ្ទេសវារៈ ។

## និទ្ទេសវារៈ

(៣៦) ទុក្ខៈ ហៅថាទុក្ខសច្ចឬ ។ អើ ។ ទុក្ខសច្ច ហៅថាទុក្ខៈឬ ។ ទុក្ខសច្ច ដ៏សេស វៀរលែងទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ហៅថាទុក្ខសច្ច មិនហៅថាទុក្ខៈ ឯទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ហៅថាទុក្ខៈផង ហៅថាទុក្ខសច្ចផង ។ សមុទយៈ ហៅថាសមុទយសច្ចឬ ។ សមុទយៈ ដ៏សេស វៀរលែងសមុទយសច្ច ហៅថាសមុទយៈ មិនហៅថា សមុទយសច្ច ឯសមុទយសច្ច ហៅថាសមុទយៈផង ហៅថាសមុទយសច្ចផង ។ សមុទយសច្ច ហៅថាសមុទយៈឬ ។ អើ ។ និរោធៈ ហៅថានិរោធសច្ចឬ ។ និរោធៈ ដ៏សេស វៀរលែងនិរោធសច្ច ហៅថា និរោធៈ មិនហៅថានិរោធសច្ច ឯនិរោធសច្ច ហៅថានិរោធៈផង ហៅថានិរោធសច្ចផង ។ និរោធសច្ច ហៅថានិរោធៈឬ ។ អើ ។ មគ្គៈ ហៅថាមគ្គសច្ចឬ ។ មគ្គៈ ដ៏សេស វៀរលែងមគ្គសច្ច ហៅថាមគ្គៈ មិនហៅថាមគ្គសច្ច ឯមគ្គសច្ច ហៅថាមគ្គៈផង ហៅថាមគ្គសច្ចផង ។ មគ្គសច្ច ហៅថាមគ្គៈឬ ។ អើ ។

## សច្ចយមកេ បណ្ណត្តិវារស្ស និទ្ទេសោ

(៣៣) ន ទុក្ខំ ន ទុក្ខសច្ចន្តិ ។ កាយិកំ ទុក្ខំ ចេតសិកំ ទុក្ខំ ឋបេត្វា អវសេសំ ទុក្ខសច្ចំ ន ទុក្ខំ ទុក្ខសច្ចំ ទុក្ខញ្ច ទុក្ខសច្ចញ្ច ឋបេត្វា អវសេសំ ន ចេវ ទុក្ខំ ន ច ទុក្ខសច្ចំ ។ ន ទុក្ខសច្ចំ ន ទុក្ខន្តិ ។ អាមន្តា ។ ន សមុទយោ ន សមុទយសច្ចន្តិ ។ អាមន្តា ។ ន សមុទយសច្ចំ ន សមុទយោតិ ។ សមុទយសច្ចំ ឋបេត្វា អវសេសោ សមុទយោ ន សមុទយសច្ចំ សមុទយោ សមុទយញ្ច សមុទយសច្ចញ្ច ឋបេត្វា អវសេសោ ន ចេវ សមុទយោ ន ច សមុទយសច្ចំ ។ ន និរោធោ ន និរោធសច្ចន្តិ ។ អាមន្តា ។ ន និរោធសច្ចំ ន និរោធោតិ ។ និរោធសច្ចំ ឋបេត្វា អវសេសោ និរោធោ ន និរោធសច្ចំ និរោធោ និរោធញ្ច និរោធសច្ចញ្ច ឋបេត្វា អវសេសោ ន ចេវ និរោធោ ន ច និរោធសច្ចំ ។ ន មគ្គោ ន មគ្គសច្ចន្តិ ។ អាមន្តា ។ ន មគ្គសច្ចំ ន មគ្គោតិ ។ មគ្គសច្ចំ ឋបេត្វា អវសេសោ មគ្គោ ន មគ្គសច្ចំ មគ្គោ មគ្គញ្ច មគ្គសច្ចញ្ច ឋបេត្វា អវសេសោ ន ចេវ មគ្គោ ន ច មគ្គសច្ចំ ។

សច្ចយមកៈ បណ្ណត្តិវារៈ និទ្ទេស

(៣៣) មិនមែនទុក្ខៈ មិនហៅថាទុក្ខសច្ចឬ ។ ទុក្ខសច្ច ដ៏សេស វៀរលែងទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត មិនហៅថាទុក្ខៈ ហៅថាទុក្ខសច្ច ឯធម្មជាត ដ៏សេស វៀរលែងទុក្ខៈ និងទុក្ខសច្ចចេញ មិនហៅថាទុក្ខៈផង មិនហៅថាទុក្ខសច្ចផង ។ មិនមែនទុក្ខសច្ច មិនហៅថាទុក្ខឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថាសមុទយសច្ចឬ ។ អើ ។ មិនមែនសមុទយសច្ច មិនហៅថាសមុទយៈឬ ។ សមុទយៈ ដ៏សេស វៀរលែងសមុទយសច្ច មិនហៅថាសមុទយសច្ច ហៅថាសមុទយៈ ឯសភាវៈដ៏សេស វៀរលែងសមុទយៈនិងសមុទយសច្ចចេញ មិនហៅថាសមុទយៈផង មិនហៅថាសមុទយសច្ចផង ។ មិនមែននិរោធៈ មិនហៅថានិរោធសច្ចឬ ។ អើ ។ មិនមែននិរោធសច្ច មិនហៅថានិរោធៈឬ ។ និរោធៈ ដ៏សេស វៀរលែងនិរោធសច្ច មិនហៅថានិរោធសច្ច ហៅថានិរោធៈ ឯសភាវៈដ៏សេស វៀរលែងនិរោធៈ និងនិរោធសច្ចចេញ មិនហៅថានិរោធៈផង មិនហៅថានិរោធសច្ចផង ។ មិនមែនមគ្គៈ មិនហៅថាមគ្គសច្ចឬ ។ អើ ។ មិនមែនមគ្គសច្ច មិនហៅថាមគ្គៈឬ ។ មគ្គៈ ដ៏សេស វៀរលែងមគ្គសច្ច មិនហៅថា មគ្គសច្ច ហៅថាមគ្គៈ ឯសភាវៈដ៏សេស វៀរលែងមគ្គៈ និងមគ្គសច្ចចេញ មិនហៅថា មគ្គៈផង មិនហៅថាមគ្គសច្ចផង ។

(៣៤) ទុក្ខំ ទុក្ខសច្ចន្តិ ។ អាមន្តា ។ សច្ចា សមុទយសច្ចន្តិ ។ សមុទយសច្ចំ សច្ចញ្ចេវ សមុទយសច្ចញ្ច អវសេសា សច្ចា សច្ចា ន សមុទយសច្ចំ ។ ទុក្ខំ ទុក្ខសច្ចន្តិ ។ អាមន្តា ។ សច្ចា និរោធសច្ចន្តិ ។ បេ ។ សច្ចា មគ្គសច្ចន្តិ ។ មគ្គសច្ចំ សច្ចញ្ចេវ មគ្គសច្ចញ្ច អវសេសា សច្ចា សច្ចា ន មគ្គសច្ចំ ។ សមុទយោ សមុទយសច្ចន្តិ ។ សមុទយសច្ចំ ឋបេត្វា អវសេសោ សមុទយោ សមុទយោ ន សមុទយសច្ចំ សមុទយសច្ចំ សមុទយោ ចេវ សមុទយសច្ចញ្ច ។ សច្ចា ទុក្ខសច្ចន្តិ ។ បេ ។ សច្ចា និរោធសច្ចន្តិ ។ បេ ។ សច្ចា មគ្គសច្ចន្តិ ។ មគ្គសច្ចំ សច្ចញ្ចេវ មគ្គសច្ចញ្ច អវសេសា សច្ចា សច្ចា ន មគ្គសច្ចំ ។ និរោធោ និរោធសច្ចន្តិ ។ និរោធសច្ចំ ឋបេត្វា អវសេសោ និរោធោ និរោធោ ន និរោធសច្ចំ និរោធសច្ចំ និរោធោ ចេវ និរោធសច្ចញ្ច ។ សច្ចា ទុក្ខសច្ចន្តិ ។ បេ ។ សច្ចា សមុទយសច្ចន្តិ ។ បេ ។ សច្ចា

(៣៤) ទុក្ខៈ ហៅថាទុក្ខសច្ចឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថា សមុទយសច្ចឬ ។ សមុទយសច្ច ហៅថាសច្ចៈផង ហៅថាសមុទយសច្ចផង សច្ចៈទាំងឡាយ ដ៏សេស ហៅថាសច្ចៈ មិនហៅថាសមុទយសច្ចទេ ។ ទុក្ខៈ ហៅថាទុក្ខសច្ចឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថា និរោធសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថាមគ្គសច្ចឬ ។ មគ្គសច្ច ហៅថាសច្ចៈផង ហៅថា មគ្គសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថាសច្ចៈ មិនហៅថាមគ្គសច្ចទេ ។ សមុទយៈ ហៅថាសមុទយសច្ចឬ ។ សមុទយៈដ៏សេស វៀរលែងសមុទយសច្ច ហៅថាសមុទយៈ មិនហៅថាសមុទយសច្ច ឯសមុទយសច្ច ហៅថាសមុទយៈផង ហៅថា សមុទយសច្ចផង ។ សច្ចៈទាំងឡាយ ហៅថាទុក្ខសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថានិរោធសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថាមគ្គសច្ចឬ ។ មគ្គសច្ច ហៅថាសច្ចៈផង ហៅថាមគ្គសច្ចផង សច្ចៈទាំងឡាយ ដ៏សេស ហៅថាសច្ចៈ មិនហៅថាមគ្គសច្ចទេ ។ និរោធៈ ហៅថានិរោធសច្ចឬ ។ និរោធៈ ដ៏សេស វៀរលែងនិរោធសច្ច ហៅថានិរោធៈ មិនហៅថានិរោធសច្ចទេ ឯនិរោធសច្ច ហៅថានិរោធៈផង ហៅថានិរោធសច្ចផង ។ សច្ចៈទាំងឡាយ ហៅថាទុក្ខសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថាសមុទយសច្ច ។ បេ ។ សច្ចៈទាំងឡាយ

មគ្គសច្ចន្តិ ។ មគ្គសច្ចំ សច្ចញ្ចេវ មគ្គសច្ចញ្ច អវសេសា សច្ចា សច្ចា ន មគ្គសច្ចំ ។ មគ្គោ មគ្គសច្ចន្តិ ។ មគ្គសច្ចំ ឋបេត្វា អវសេសោ មគ្គោ មគ្គោ ន មគ្គសច្ចំ មគ្គសច្ចំ មគ្គោ ចេវ មគ្គសច្ចញ្ច ។ សច្ចា ទុក្ខសច្ចន្តិ ។ បេ ។ សច្ចា សមុទយសច្ចន្តិ ។ បេ ។ សច្ចា និរោធសច្ចន្តិ ។ និរោធសច្ចំ សច្ចញ្ចេវ និរោធសច្ចញ្ច អវសេសា សច្ចា សច្ចា ន និរោធសច្ចំ ។

(៣៥) ន ទុក្ខំ ន ទុក្ខសច្ចន្តិ ។ កាយិកំ ទុក្ខំ ចេតសិកំ ទុក្ខំ ឋបេត្វា អវសេសំ ទុក្ខសច្ចំ ន ទុក្ខំ ទុក្ខសច្ចំ ទុក្ខញ្ច ទុក្ខសច្ចញ្ច ឋបេត្វា អវសេសា ន ចេវ ទុក្ខំ ន ច ទុក្ខសច្ចំ ។ ន សច្ចា ន សមុទយសច្ចន្តិ ។ អាមន្តា ។ ន ទុក្ខំ ន ទុក្ខសច្ចន្តិ ។ កាយិកំ ទុក្ខំ ចេតសិកំ ទុក្ខំ ឋបេត្វា អវសេសំ ទុក្ខសច្ចំ ន ទុក្ខំ ទុក្ខសច្ចំ ទុក្ខញ្ច ទុក្ខសច្ចញ្ច ឋបេត្វា អវសេសា[១] ន ចេវ ទុក្ខំ ន ច ទុក្ខសច្ចំ ។ ន សច្ចា ន និរោធសច្ចន្តិ ។ បេ ។ ន សច្ចា ន មគ្គសច្ចន្តិ ។

១ ម. អវសេសំ ។

ហៅថាមគ្គសច្ចឬ ។ មគ្គសច្ច ហៅថាសច្ចៈផង ហៅថាមគ្គសច្ចផង សច្ចៈទាំងឡាយ ដ៏សេស ហៅថាសច្ចៈ មិនហៅថាមគ្គសច្ចទេ ។ មគ្គៈ ហៅថាមគ្គសច្ចឬ ។ មគ្គៈ ដ៏សេស វៀរលែងមគ្គសច្ច ហៅថាមគ្គៈ មិនហៅថាមគ្គសច្ចទេ ឯមគ្គសច្ច ហៅថាមគ្គៈផង ហៅថាមគ្គសច្ចផង ។ សច្ចៈទាំងឡាយ ហៅថាទុក្ខសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថាសមុទយសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថានិរោធសច្ចឬ ។ និរោធសច្ច ហៅថាសច្ចៈផង ហៅថានិរោធសច្ចផង សច្ចៈទាំងឡាយ ដ៏សេស ហៅថាសច្ចៈ មិនហៅថានិរោធសច្ចទេ ។

(៣៤) មិនមែនទុក្ខៈ មិនហៅថាទុក្ខសច្ចឬ ។ ទុក្ខសច្ច ដ៏សេស វៀរលែងទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្តចេញ មិនហៅថាទុក្ខៈ ហៅថាទុក្ខសច្ច ធម្មជាត ដ៏សេស វៀរលែងទុក្ខៈនិងទុក្ខសច្ចចេញ មិនហៅថាទុក្ខៈផង មិនហៅថាទុក្ខសច្ចផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ចឬ ។ អើ ។ មិនមែនទុក្ខៈ មិនហៅថាទុក្ខសច្ចឬ ។ ទុក្ខសច្ច ដ៏សេស វៀរលែងទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្តចេញ មិនហៅថាទុក្ខៈ ហៅថាទុក្ខ-សច្ច ធម្មជាត ដ៏សេស វៀរលែងទុក្ខៈនិងទុក្ខសច្ចចេញ មិនហៅថាទុក្ខៈផង មិនហៅថាទុក្ខសច្ចផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថានិរោធសច្ចឬ ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គសច្ចឬ ។

អាមន្តា ។ ន សមុទយោ ន សមុទយសច្ចន្តិ ។ អាមន្តា ។ ន សច្ចា ន ទុក្ខសច្ចន្តិ ។ អាមន្តា ។ ន សមុទយោ ន សមុទយសច្ចន្តិ ។ អាមន្តា ។ ន សច្ចា ន និរោធសច្ចន្តិ ។ បេ ។ ន សច្ចា ន មគ្គសច្ចន្តិ ។ អាមន្តា ។ ន និរោធោ ន និរោធសច្ចន្តិ ។ អាមន្តា ។ ន សច្ចា ន ទុក្ខសច្ចន្តិ ។ បេ ។ ន សច្ចា ន សមុទយសច្ចន្តិ ។ បេ ។ ន សច្ចា ន មគ្គសច្ចន្តិ ។ អាមន្តា ។ ន មគ្គោ ន មគ្គសច្ចន្តិ ។ អាមន្តា ។ ន សច្ចា ន ទុក្ខសច្ចន្តិ ។ អាមន្តា ។ ន មគ្គោ ន មគ្គសច្ចន្តិ ។ អាមន្តា ។ ន សច្ចា ន សមុទយសច្ចន្តិ ។ បេ ។ ន សច្ចា ន និរោធសច្ចន្តិ ។ អាមន្តា ។

(៣៦) ទុក្ខំ សច្ចន្តិ ។ អាមន្តា ។ សច្ចា ទុក្ខសច្ចន្តិ ។ ទុក្ខសច្ចំ សច្ចញ្ចេវ ទុក្ខសច្ចញ្ច អវសេសា សច្ចា សច្ចា ន ទុក្ខសច្ចំ ។ សមុទយោ សច្ចន្តិ ។ អាមន្តា ។ បេ ។ និរោធោ សច្ចន្តិ ។

អើ ។ មិនមែនសមុទយៈ មិនហៅថាសមុទយសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខសច្ចឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថាសមុទយសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថានិរោធសច្ច ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គសច្ចឬ ។ អើ ។ មិនមែននិរោធ មិនហៅថានិរោធសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខសច្ចឬ ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយសច្ចឬ ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គសច្ចឬ ។ អើ ។ មិនមែនមគ្គ មិនហៅថាមគ្គសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខសច្ចឬ ។ អើ ។ មិនមែនមគ្គ មិនហៅថាមគ្គសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយសច្ចឬ ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថានិរោធសច្ចឬ ។ អើ ។

(៣៦) ទុក្ខ ហៅថាសច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថាទុក្ខសច្ចឬ ។ ទុក្ខសច្ច ហៅថាសច្ចៈផង ហៅថាទុក្ខសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថាសច្ចៈ មិនហៅថាទុក្ខសច្ចទេ ។ សមុទយៈ ហៅថាសច្ចៈឬ ។ អើ ។ បេ ។ និរោធ ហៅថាសច្ចៈឬ ។

អាមន្តា ។ បេ ។ មគ្គោ សច្ចន្តិ ។ អាមន្តា ។ សច្ចា មគ្គសច្ចន្តិ ។ មគ្គសច្ចំ សច្ចញ្ចេវ មគ្គសច្ចញ្ច អវសេសា សច្ចា សច្ចា ន មគ្គសច្ចំ ។

(៣៧) ន ទុក្ខំ ន សច្ចន្តិ ។ ទុក្ខំ ឋបេត្វា អវសេសា សច្ចា ន ទុក្ខំ សច្ចា ទុក្ខញ្ច សច្ចញ្ច ឋបេត្វា អវសេសា ន ចេវ ទុក្ខំ ន ច សច្ចា ។ ន សច្ចា ន ទុក្ខសច្ចន្តិ ។ អាមន្តា ។ ន សមុទយោ ន សច្ចន្តិ ។ សមុទយំ ឋបេត្វា ។ បេ ។ ន និរោធោ ន សច្ចន្តិ ។ និរោធំ ឋបេត្វា ។ បេ ។ ន មគ្គោ ន សច្ចន្តិ ។ មគ្គំ ឋបេត្វា អវសេសា សច្ចា ន មគ្គោ សច្ចា មគ្គញ្ច សច្ចញ្ច ឋបេត្វា អវសេសា ន ចេវ មគ្គោ ន ច សច្ចា ។ ន សច្ចា ន មគ្គសច្ចន្តិ ។ អាមន្តា ។

(៣៨) ទុក្ខំ សច្ចន្តិ ។ អាមន្តា ។ សច្ចា សមុទយសច្ចន្តិ ។ សមុទយសច្ចំ សច្ចញ្ចេវ សមុទយសច្ចញ្ច អវសេសា សច្ចា សច្ចា ន សមុទយសច្ចំ ។ ទុក្ខំ សច្ចន្តិ ។ អាមន្តា ។ សច្ចា និរោធសច្ចន្តិ ។ បេ ។ សច្ចា មគ្គសច្ចន្តិ ។ មគ្គសច្ចំ

អើ ។ បេ ។ មគ្គ ហៅថាសច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថាមគ្គសច្ចឬ ។ មគ្គសច្ច ហៅថាសច្ចៈផង ហៅថាមគ្គសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថាសច្ចៈ មិនហៅថាមគ្គសច្ចទេ ។

(៣៧) មិនមែនទុក្ខ មិនហៅថាសច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងទុក្ខ មិនហៅថាទុក្ខ ហៅថាសច្ចៈ ធម្មជាតដ៏សេស វៀរលែងទុក្ខ និងសច្ចៈចេញ មិនហៅថាទុក្ខផង មិនហៅថាសច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខសច្ចឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថាសច្ចៈឬ ។ (សច្ចៈដ៏សេស) វៀរលែងសមុទយៈ ។ បេ ។ មិនមែននិរោធ មិនហៅថាសច្ចៈឬ ។ ( សច្ចៈដ៏សេស ) វៀរលែងនិរោធ ។ បេ ។ មិនមែនមគ្គ មិនហៅថាសច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងមគ្គ មិនហៅថាមគ្គ ហៅថាសច្ចៈ ធម្មជាតដ៏សេស វៀរលែងមគ្គ និងសច្ចៈចេញ មិនហៅថាមគ្គផង មិនហៅថាសច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គសច្ចឬ ។ អើ ។

(៣៨) ទុក្ខ ហៅថាសច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថាសមុទយសច្ចឬ ។ សមុទយសច្ច ហៅថាសច្ចៈផង ហៅថាសមុទយសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថាសច្ចៈ មិនហៅថាសមុទយសច្ចទេ ។ ទុក្ខ ហៅថាសច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថានិរោធសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថាមគ្គសច្ចឬ ។ មគ្គសច្ច

សច្ចញ្ចេវ មគ្គសច្ចញ្ច អវសេសា សច្ចា សច្ចា ន មគ្គ-
សច្ចំ ។ សមុទយោ សច្ចន្តិ ។ អាមន្តា ។ បេ ។ និរោ-
ធោ សច្ចន្តិ ។ អាមន្តា ។ បេ ។ មគ្គោ សច្ចន្តិ ។
អាមន្តា ។ សច្ចា ទុក្ខសច្ចន្តិ ។ បេ ។ សច្ចា សមុ-
ទយសច្ចន្តិ ។ បេ ។ សច្ចា និរោធសច្ចន្តិ ។ និរោ-
ធសច្ចំ សច្ចញ្ចេវ និរោធសច្ចញ្ច អវសេសា សច្ចា
សច្ចា ន និរោធសច្ចំ ។

(៣៩) ន ទុក្ខំ ន សច្ចន្តិ ។ ទុក្ខំ ឋបេត្វា អវ-
សេសា សច្ចា ន ទុក្ខំ សច្ចា ទុក្ខញ្ច សច្ចញ្ច
ឋបេត្វា អវសេសា ន ចេវ ទុក្ខំ ន ច សច្ចា ។
ន សច្ចា ន សមុទយសច្ចន្តិ ។ អាមន្តា ។ ន ទុក្ខំ
ន សច្ចន្តិ ។ ទុក្ខំ ឋបេត្វា អវសេសា សច្ចា ន
ទុក្ខំ សច្ចា ទុក្ខញ្ច សច្ចញ្ច ឋបេត្វា អវសេសា
ន ចេវ ទុក្ខំ ន ច សច្ចា ។ ន សច្ចា ន
និរោធសច្ចន្តិ ។ បេ ។ ន សច្ចា ន មគ្គ-
សច្ចន្តិ ។ អាមន្តា ។ ន សមុទយោ ន សច្ចន្តិ ។

ហៅថាសច្ចៈផង ហៅថាមគ្គសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថាសច្ចៈ មិនហៅថាមគ្គសច្ចទេ ។ សមុទយៈ ហៅថាសច្ចៈឬ ។ អើ ។ បេ ។ និរោធ ហៅថាសច្ចៈឬ ។ អើ ។ បេ ។ មគ្គ ហៅថាសច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថាទុក្ខសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថាសមុទយសច្ច ។ បេ ។ សច្ចៈទាំងឡាយ ហៅថានិរោធសច្ចឬ ។ និរោធសច្ច ហៅថាសច្ចៈផង ហៅថានិរោធសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថាសច្ចៈ មិនហៅថានិរោធសច្ចទេ ។

(៣៩) មិនមែនទុក្ខ មិនហៅថាសច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងទុក្ខ មិនហៅថាទុក្ខ ហៅថាសច្ចៈ ធម្មជាតដ៏សេស វៀរលែងទុក្ខ និងសច្ចៈចេញ មិនហៅថាទុក្ខផង មិនហៅថាសច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយសច្ចឬ ។ អើ ។ មិនមែនទុក្ខ មិនហៅថាសច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងទុក្ខ មិនហៅថាទុក្ខ ហៅថាសច្ចៈ ធម្មជាតដ៏សេស វៀរលែងទុក្ខ និងសច្ចៈចេញ មិនហៅថាទុក្ខផង មិនហៅថាសច្ចៈផង មិនមែនសច្ចៈទាំងឡាយ មិនហៅថានិរោធសច្ចឬ ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាមគ្គសច្ចឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថាសច្ចៈឬ ។

សមុទយំ ឋបេត្វា អវសេសា សច្ចា ន សមុទយោ សច្ចា សមុទយញ្ច សច្ចញ្ច ឋបេត្វា អវសេសា ន ចេវ សមុទយោ ន ច សច្ចា ។ បេ ។ ន និរោធោ ន សច្ចន្តិ ។ និរោធំ ឋបេត្វា ។ បេ ។ ន មគ្គោ ន សច្ចន្តិ ។ មគ្គំ ឋបេត្វា អវសេសា សច្ចា ន មគ្គោ សច្ចា មគ្គញ្ច សច្ចញ្ច ឋបេត្វា អវសេសា ន ចេវ មគ្គោ ន ច សច្ចា ។ ន សច្ចា ន ទុក្ខសច្ចន្តិ ។ អាមន្តា ។ ន មគ្គោ ន សច្ចន្តិ ។ មគ្គំ ឋបេត្វា អវសេសា សច្ចា ន មគ្គោ សច្ចា មគ្គញ្ច សច្ចញ្ច ឋបេត្វា អវសេសា ន ចេវ មគ្គោ ន ច សច្ចា ។ ន សច្ចា ន សមុទយសច្ចន្តិ ។ បេ ។ ន សច្ចា ន និរោធសច្ចន្តិ ។ អាមន្តា ។

បណ្ណត្តិវារោ ។

## បវត្តិវារោ

(៤០) យស្ស ទុក្ខសច្ចំ ឧប្បជ្ជតិ តស្ស សមុទយសច្ចំ ឧប្បជ្ជតីតិ ។ សព្វេសំ ឧបបជ្ជន្តានំ

សច្ចយមកៈ បវត្តិវារៈ ឧប្បាទវារៈ

សច្ចៈទាំងឡាយដ៏សេស វៀរលែងសមុទយៈ មិនហៅថាសមុទយៈ ហៅថាសច្ចៈ ធម្មជាតដ៏សេស វៀរលែងសមុទយៈ និងសច្ចៈចេញ មិនហៅថាសមុទយៈផង មិនហៅថាសច្ចៈផង ។ បេ ។ មិនមែននិរោធ មិនហៅថាសច្ចៈឬ ។ (សច្ចៈទាំងឡាយដ៏សេស) វៀរលែងនិរោធ ។ បេ ។ មិនមែនមគ្គ មិនហៅថាសច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងមគ្គ មិនហៅថាមគ្គ ហៅថាសច្ចៈ ធម្មជាតដ៏សេស វៀរលែងមគ្គ និងសច្ចៈចេញ មិនហៅថាមគ្គផង មិនហៅថាសច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាទុក្ខសច្ចឬ ។ អើ ។ មិនមែនមគ្គ មិនហៅថាសច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងមគ្គ មិនហៅថាមគ្គ ហៅថាសច្ចៈ ធម្មជាតដ៏សេស វៀរលែងមគ្គ និងសច្ចៈចេញ មិនហៅថាមគ្គផង មិនហៅថាសច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថាសមុទយសច្ចឬ ។ បេ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថានិរោធ-សច្ចឬ ។ អើ ។

ចប់ បណ្ណត្តិវារៈ ។

# បវត្តិវារៈ

(៤០) ទុក្ខសច្ច របស់សត្វណា កើតឡើង សមុទយសច្ច របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ

បវត្តេ តណ្ហាវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ តេសំ ទុក្ខសច្ចំ ឧប្បជ្ជតិ នោ ច តេសំ សមុទយសច្ចំ ឧប្បជ្ជតិ តណ្ហាយ ឧប្បាទក្ខណេ តេសំ ទុក្ខសច្ចញ្ច ឧប្បជ្ជតិ សមុទយសច្ចញ្ច ឧប្បជ្ជតិ ។ យស្ស វា បន សមុទយសច្ចំ ឧប្បជ្ជតិ តស្ស ទុក្ខសច្ចំ ឧប្បជ្ជតីតិ ។ អាមន្តា ។

(៤១) យស្ស ទុក្ខសច្ចំ ឧប្បជ្ជតិ តស្ស មគ្គសច្ចំ ឧប្បជ្ជតីតិ ។ សព្វេសំ ឧបបជ្ជន្តានំ បវត្តេ មគ្គវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ តេសំ ទុក្ខសច្ចំ ឧប្បជ្ជតិ នោ ច តេសំ មគ្គសច្ចំ ឧប្បជ្ជតិ ។ បញ្ចវោការេ មគ្គស្ស ឧប្បាទក្ខណេ តេសំ ទុក្ខសច្ចញ្ច ឧប្បជ្ជតិ មគ្គសច្ចញ្ច ឧប្បជ្ជតិ ។ យស្ស វា បន មគ្គសច្ចំ ឧប្បជ្ជតិ តស្ស ទុក្ខសច្ចំ ឧប្បជ្ជតីតិ ។ អរូបេ មគ្គស្ស ឧប្បាទក្ខណេ តេសំ មគ្គសច្ចំ ឧប្បជ្ជតិ នោ ច តេសំ ទុក្ខសច្ចំ ឧប្បជ្ជតិ ។ បញ្ចវោការេ មគ្គស្ស ឧប្បាទក្ខណេ តេសំ មគ្គសច្ចញ្ច ឧប្បជ្ជតិ ទុក្ខសច្ចញ្ច ឧប្បជ្ជតិ ។

ទុក្ខសច្ច របស់សត្វទាំងនោះ រមែងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកតណ្ហា ក្នុងកាលជាបច្ចុប្បន្ន ឯសមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ទុក្ខសច្ច របស់សត្វទាំងនោះ រមែងកើតឡើងផង សមុទយសច្ច រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ។ មួយទៀត សមុទយសច្ច របស់សត្វណា កើតឡើង ទុក្ខសច្ច របស់សត្វនោះ រមែងកើតឡើងឬ ។ អើ ។

(៤១) ទុក្ខសច្ច របស់សត្វណា កើតឡើង មគ្គសច្ច របស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ទុក្ខ-សច្ច របស់សត្វទាំងនោះ រមែងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកមគ្គ ក្នុងបច្ចុប្បន្ន ឯមគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ទុក្ខសច្ច របស់សត្វទាំងនោះ រមែងកើតឡើងផង មគ្គសច្ច រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈ នៃមគ្គ ក្នុងបញ្ចវោការភព ។ មួយទៀត មគ្គសច្ច របស់សត្វណា កើតឡើង ទុក្ខសច្ច របស់សត្វនោះ រមែងកើតឡើងឬ ។ មគ្គសច្ច របស់សត្វទាំងនោះ រមែងកើតឡើង ក្នុងឧប្បាទក្ខណៈនៃមគ្គ ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ មគ្គសច្ច របស់សត្វទាំងនោះ រមែងកើតឡើងផង ទុក្ខសច្ច រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃមគ្គ ក្នុងបញ្ចវោការភព ។

សច្ចយមកេ បវត្តិវារស្ស ឧប្បាទវារោ

(៤២) យស្ស សមុទយសច្ចំ ឧប្បជ្ជតិ តស្ស មគ្គសច្ចំ ឧប្បជ្ជតីតិ ។ នោ ។ យស្ស វា បន មគ្គសច្ចំ ឧប្បជ្ជតិ តស្ស សមុទយសច្ចំ ឧប្បជ្ជតីតិ ។ នោ ។

(៤៣) យត្ថ ទុក្ខសច្ចំ ឧប្បជ្ជតិ តត្ថ សមុទយសច្ចំ ឧប្បជ្ជតីតិ ។ អសញ្ញសត្តេ តត្ថ ទុក្ខសច្ចំ ឧប្បជ្ជតិ នោ ច តត្ថ សមុទយសច្ចំ ឧប្បជ្ជតិ ចតុវោការេ បញ្ចវោការេ តត្ថ ទុក្ខសច្ចញ្ច ឧប្បជ្ជតិ សមុទយសច្ចញ្ច ឧប្បជ្ជតិ ។ យត្ថ វា បន សមុទយសច្ចំ ឧប្បជ្ជតិ តត្ថ ទុក្ខសច្ចំ ឧប្បជ្ជតីតិ ។ អាមន្តា ។

(៤៤) យត្ថ ទុក្ខសច្ចំ ឧប្បជ្ជតិ តត្ថ មគ្គសច្ចំ ឧប្បជ្ជតីតិ ។ អបាយេ អសញ្ញសត្តេ តត្ថ ទុក្ខសច្ចំ ឧប្បជ្ជតិ នោ ច តត្ថ មគ្គសច្ចំ ឧប្បជ្ជតិ អវសេសេ ចតុវោការេ បញ្ចវោការេ តត្ថ ទុក្ខសច្ចញ្ច ឧប្បជ្ជតិ មគ្គសច្ចញ្ច ឧប្បជ្ជតិ ។ យត្ថ វា បន មគ្គសច្ចំ ឧប្បជ្ជតិ តត្ថ ទុក្ខសច្ចំ ឧប្បជ្ជតីតិ ។ អាមន្តា ។

សច្ចយមកៈ បវត្តិវារៈ ឧប្បាទវារៈ

(៦២) សមុទយសច្ច របស់សត្វណា កើតឡើង មគ្គសច្ច របស់សត្វនោះ រមែងកើតឡើងឬ ។ មិនកើតឡើងទេ ។ មួយទៀត មគ្គសច្ច របស់សត្វណា កើតឡើង សមុទយសច្ច របស់សត្វនោះ រមែងកើតឡើងឬ ។ មិនកើតឡើងទេ ។

